# ព្រឹត្តិបត្រមេធាវី

លេខ ១៦

ខែ មករា-មីនា ឆ្នាំ ២០១៨

រក្សាសិទ្ធិ © 2018 គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

មតិដែលសំដែងនៅក្នុងព្រឹត្តិបត្រនេះ គឺជាមតិរបស់អ្នកនិពន្ធផ្ទាល់ ហើយមិនបញ្ជាំងនូវទស្សនៈរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

ស្របតាមគោលការណ៍សេរីភាពនៃការបញ្ចេញមតិ ដែលជាគោលការណ៍គ្រឹះ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីគាំទ្រឱ្យមានភាពចម្រុះនៃមតិនានា។

សូមរក្សាសិទ្ធិ © ដោយអនុលោមតាមច្បាប់ស្តីពី "សិទ្ធិអ្នកនិពន្ធ និងប្រហាក់ប្រហែល" ដែលត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ ហើយរាល់ការថតចម្លងឡើងវិញ ដោយគ្មានការអនុញ្ញាតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់។

**ទំព័រ**

# មាតិកា


**សារពីប្រធានគណៈមេធាវី** ..... IV

## ផ្នែកព្រហ្មទណ្ឌ

**សង្ខេបយុត្តិសាស្ត្រ សំណុំរឿងលេខ ០០១, អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចស្តីពី អញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី, ២៦ ខែ កក្កដា ឆ្នាំ ២០១០** ..... 1

១. សេចក្តីផ្តើម ..... 1

២. អាជ្ញាយុកាលនៃបទឧក្រិដ្ឋ ..... 1

៣. កំណត់សំគាល់ ..... 4

## ផ្នែករដ្ឋប្បវេណី

**កំហុសដោយខ្សែក សំណង និង ការមិនទទួលខុសត្រូវក្នុងអំពើអនីត្យានុកូល** ..... 9

១. សេចក្តីផ្តើម ..... 9

២. ខ្លឹមសារ ..... 9

៣. សង្ខេប ..... 14

**មូលដ្ឋានក្នុងការបដិសេធការទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស នៅក្នុងច្បាប់កម្ពុជា** ..... 15

១. សេចក្តីផ្តើម ..... 15

២. មូលដ្ឋានដើម្បីបដិសេធការទទួលស្គាល់ ឬ/និងការប្រតិបត្តិ ..... 17

១. មោឃភាពនៃកិច្ចសន្យាមជ្ឈត្តកម្ម ........................................................18
២. វិវាទមិនមែនពាណិជ្ជកម្ម........................................................................19
៣. ខ្វះការជូនដំណឹង ឬយុត្តិធម៌ ...................................................................19
៤. វេទិកា ឬនីតិវិធី នៃមជ្ឈត្តការ មិនស្របតាមការព្រមព្រៀងរបស់ភាគី ...........20
៥. មជ្ឈត្តវិនិច្ឆ័យដែលមិនទាន់មានអនុភាព ចងកាតព្វកិច្ចរបស់គូភាគី ឬត្រូវបាន លុបចោល ដោយតុលាការនៃប្រទេស ដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានចេញ......................21
៣. សេចក្តីសន្និដ្ឋាន..................................................................................24
**ហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ** ...............................................27
១. សេចក្តីផ្តើម.........................................................................................27
ជំពូកទី ១៖ ការទទួលបានហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ...........................31
ការបង្កើតកិច្ចសន្យា ...................................................................................35
កថាខណ្ឌ ទី១៖ កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ........................................36
កថាខណ្ឌ ទី២៖ ប្រាតិភោគ ...........................................................................40
១. ប្រាតិភោគប្រក្សត្យ.................................................................................40
២.ប្រាតិភោគបុគ្គល......................................................................................41
ជំពូកទី ២៖ ការអនុវត្តកិច្ចសន្យាហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ ....................42
ផ្នែកទី១៖ សិទ្ធិ និង កាតព្វកិច្ចរបស់ម្ចាស់គម្រោង.......................................................42
កថាខណ្ឌទី១. សិទ្ធិរបស់ម្ចាស់គម្រោង .................................................................42
កថាខណ្ឌទី២.កាតព្វកិច្ចរបស់ម្ចាស់គម្រោង ...........................................................43
១.កាតព្វកិច្ចតាមការកំណត់នៅក្នុងក្រមរដ្ឋប្បវេណី.......................................................43
២. កាតព្វកិច្ចនៅក្នុងទិដ្ឋភាពនៃការអនុវត្តជាក់ស្តែង .....................................................44
ផ្នែកទី២ ៖ សិទ្ធិ និង កាតព្វកិច្ចរបស់ហិរញ្ញប្បទានិក.................................................46

កថាខណ្ឌទី១. សិទ្ធិ របស់ហិរញ្ញប្បទានិក ....................................................................46
កថាខណ្ឌទី២.កាតព្វកិច្ចរបស់ហិរញ្ញប្បទានិក.............................................................49
២. សេចក្តីសន្និដ្ឋាន .....................................................................................................50

## សកម្មភាពរបស់គណៈមេធាវី

១. ទំនាក់ទំនងជាតិ និងអន្តរជាតិ ................................................................................55
១.១ ទំនាក់ទំនងជាតិ ..............................................................................................55
១.២ ទំនាក់ទំនងអន្តរជាតិ..........................................................................................61
២. កិច្ចប្រជុំផ្ទៃក្នុង .......................................................................................................63
៣. សិក្ខាសាលា និងការផ្សព្វផ្សាយច្បាប់ ......................................................................67
៣.១ សិក្ខាសាលា ....................................................................................................67
៣.២ ការផ្សព្វផ្សាយច្បាប់តាមស្ថានីយ៍ទូរស្សន៍...........................................................70

# សារពីប្រធានគណៈមេធាវី



គណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជាមានកិត្តិយស សូមបោះពុម្ពបន្តនូវ ព្រឹត្តិបត្រមេធាវីលេខ ១៦ សម្រាប់ត្រីមាសទី ១ ខែមករា-មីនា ឆ្នាំ២០១៨។ ព្រឹត្តិបត្រមេធាវីនេះបានសម្រេចឡើងដោយ ការប្រឹងប្រែង លះបង់ពេលវេលាដ៏មានតម្លៃរបស់អ្នកនិពន្ធនីមួយៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់។ តាងនាមឱ្យគណៈមេធាវី ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកនិពន្ធ ដែលបានរួមចំណែក វិភាគទានអត្ថបទរបស់ខ្លួន។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកអគ្គលេខាធិការ លោកអគ្គលេខាធិការរងប្រធាន បុគ្គលិក និងអ្នកស្ម័គ្រចិត្ត នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃគណៈមេធាវីដែលបានខិតខំរៀបចំពិនិត្យ និងសម្រួលអត្ថបទ និងការបោះពុម្ពព្រឹត្តិបត្រលេខនេះ។

ព្រឹត្តិបត្រលេខនេះប្រមូលផ្តុំនូវអត្ថបទនៅក្នុងវិស័យនានានៃច្បាប់ ដូចជា ការប្រៀបធៀបប្រព័ន្ធតុលាការកំពូល ច្បាប់រដ្ឋប្បវេណី និងច្បាប់ពាណិជ្ជកម្មជាដើម។ បន្ថែមលើការផ្សាយនូវអត្ថបទច្បាប់ ព្រឹត្តិបត្រមេធាវីបានផ្តល់ព័ត៌មានស្តីពី សកម្មភាពនៃគណៈមេធាវីដើម្បីឲ្យសហ–ភាតាជាមេធាវីបានជ្រាបពីកិច្ចដំណើរការនៃ គណៈមេធាវី។ គណៈមេធាវីនឹងស្វះស្វែងទាក់ទងមេធាវី និងអ្នកច្បាប់ដទៃទៀត ដើម្បីពង្រីកការចែករំលែកនូវចំណេះដឹងនៅក្នុងវិស័យដទៃទៀត នៅក្នុងការផ្សាយលើកក្រោយៗ។

ការបោះពុម្ពផ្សាយព្រឹត្តិបត្រមេធាវីនេះជាការឆ្លើយតបទៅនឹង**ទិសដៅទី ២ "ពង្រឹង និងការពារវិជ្ជាជីវៈ"** **នៃផែនការសកម្មភាពនៃគណៈមេធាវី** ដែលបានអនុម័តដោយក្រុមប្រឹក្សា-គណៈមេធាវី។

ខ្ញុំសង្កេតឃើញថា នៅក្នុងសហគមន៍អ្នកច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង មានអ្នកជំនាញខាងច្បាប់ជាច្រើន ដែលបានសរសេរផ្សព្វផ្សាយសៀវភៅសិក្សា ដើម្បីបម្រើសេចក្តីត្រូវការនៃអ្នកសិក្សាច្បាប់។ ទោះបីមិនមែនជាអ្នកជំនាញក៏ដោយ ខ្ញុំសូមលើកទឹកចិត្តដល់មេធាវី និងអ្នកសិក្សាទូទៅចូលរួមវិភាគទានអត្ថបទ ដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី។

គណៈមេធាវីស្វាគមន៍ជានិច្ចដល់ការចូលរួមចែករំលែកអត្ថបទរបស់ខ្លួននៅក្នុងព្រឹត្តិបត្រនេះ។ ចំពោះអ្នកដែលមានបំណិនខាងសរសេរមានកម្រិត គណៈមេធាវីមានក្រុមបណ្ណាធិការមួយ ដែលនឹងជួយផ្តល់ការណែនាំដល់អ្នកចូលរួម និងជួយកែសម្រួលអត្ថបទ។ គោលដៅនៃការបង្កើតព្រឹត្តិបត្រនេះ មិនត្រឹមតែផ្សព្វផ្សាយអត្ថបទនៃអ្នកនិពន្ធជើងចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកស្ទួយបំណិនខាងសរសេរដល់អ្នកនិពន្ធជំនាន់ក្រោយផងដែរ។

ខ្ញុំយល់ឃើញថា ថ្វីបើក្រុមបណ្ណាធិការបានផ្ចិតផ្ចង់ក្នុងការធ្វើឲ្យព្រឹត្តិបត្រទទួលបានគុណភាពមួយដ៏ខ្ពស់ក៏ដោយ ការខ្វះខាតគង់តែជៀសមិនផុត។ ដើម្បីជ្រោមជ្រែងឲ្យព្រឹត្តិបត្រនេះមានគុណភាពកាន់តែប្រសើរ ខ្ញុំសូមអំពាវនាវដល់អ្នកអានមេត្តាសរសេរតប និងរិះគន់ស្ថាបនា ធ្វើអត្ថាធិប្បាយ ឬបំពេញបន្ថែមទៅលើអត្ថបទនីមួយៗដែលបានបោះពុម្ពផ្សាយ។ ខ្ញុំសង្ឃឹមថា សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីនឹងបានរីករាយក្នុងការអានព្រឹត្តិបត្រមេធាវីលេខនេះ។

ចំពោះការចូលរួមវិភាគអត្ថបទ សូមធ្វើការទាក់ទងមកការិយាល័យគណៈមេធាវីដោយផ្ទាល់តាមរយៈលោកមេធាវី **ភុយ នាម** តាមអ៊ីម៉ែល neam130@bakc.org.kh និងលោកមេធាវី **កែ ប៊ុនធឿន** តាមអ៊ីម៉ែល bunthoeurn@bakc.org.kh ក៏បាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ សូមជួបតែជោគជ័យគ្រប់ប្រការ។

សូមអរគុណ!

ថ្ងៃសុក្រ ១៤កើត ខែចេត្រ ឆ្នាំ ច នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨



**សួន វិសាល**

ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា

# ផ្នែកព្រហ្មទណ្ឌ

# សង្ខេបយុត្តិសាស្រ្ត សំណុំរឿងលេខ ០០១, អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចស្តីពី អញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី, ២៦ ខែ កក្កដា ឆ្នាំ ២០១០

ដោយមេធាវី មាស ប៊ូរ៉ា*

## ១. សេចក្តីផ្តើម

ច្បាប់ដែលនឹងត្រូវបានយកមកប្រើដោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក) មានដូចជា ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលនៅជាធរមាន និងត្រូវបានអនុម័តនៅមុនឆ្នាំ១៩៧៥ ជាពេលវេលា បទល្មើសព្រហ្មទណ្ឌត្រូវបានចាប់ផ្តើមប្រព្រឹត្តដោយកម្មាភិបាលខ្មែរក្រហម។ ការយកច្បាប់មានជាធរមានមុនអំពើល្មើសប្រព្រឹត្តមកប្រើ គឺដើម្បីកុំឲ្យមានការខុសឆ្គងនឹងគោលការណ៍នីត្យានុកូលភាព (the Principle of Legality)។ ទោះបីជាយ៉ាងនេះក្តី នៅមានឧបសគ្គផ្លូវច្បាប់មួយចំនួនទៀតដែល អវតក បានប្រឈម។

## ២. អាជ្ញាយុកាលនៃបទឧក្រិដ្ឋ

អាជ្ញាយុកាលសម្រាប់ការចោទប្រកាន់បទឧក្រិដ្ឋចែងក្នុង ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មានរយៈពេល១០ ឆ្នាំ ដែលជាទូទៅគិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។[1] នោះគឺ ឆ្នាំ១៩៧៥។ ការគិតបែបសាមញ្ញ ប្រសិនបើមិនមានឧបសគ្គអ្វីទេ រហូតដល់ឆ្នាំ១៩៨៥ តុលាការនឹងមិនអាចចោទប្រកាន់មេដឹកនាំខ្មែរក្រហមបានទៀតឡើយ។ ច្បាប់ស្តីពីការបង្កើត អវតក ត្រូវបានអនុម័តក្នុងឆ្នាំ២០០៤ ហើយចែងរយៈពេលអាជ្ញាយុកាល ៣០ឆ្នាំ[2] ដែលសរុប ៤០ បើបូកបន្ថែម នឹង ១០ឆ្នាំចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ក្នុងន័យនេះ ចាប់តាំងពីឆ្នាំ១៩៧៥ រហូតដល់ ២០១៥ ឬ២០១៩ បើគិតពីឆ្នាំ១៩៧៩ អវតក អាចនៅតែបន្តការចោទប្រកាន់បទល្មើសក្រោម

---

* អ្នកនិពន្ធជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈត្តករពាណិជ្ជកម្ម និងសាស្រ្តាចារ្យច្បាប់។

[1] រយៈពេលអាជ្ញាយុកាលនៃទោស ចាប់គិត ពេលដែលសេចក្តីសម្រេចផ្តន្ទាទោស បានក្លាយទៅជាស្ថាពរ មាត្រា ១៤៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។ ជាទូទៅវាចាប់ផ្តើមគិតចាប់ពីថ្ងៃដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តចប់រួចរាល់, Ruth Alberdina Kok, អាជ្ញាយុកាល ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឆ្នាំ ២០០៧ ទំ. ២៩។

[2] ច្បាប់ ស្តីពី ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា ៣(ថ្មី)។

ច្បាប់ជាតិបាន។ មេធាវីការពារជនត្រូវចោទឌុច (មេធាវី) ក្នុងបំណងបន្ថយការទទួលខុសត្រូវរបស់ឌុច តាមរយៈការមិនចោទប្រកាន់បទល្មើសប្រឆាំងនឹងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងផ្អែកលើមន្ទិលថាអាជ្ញាយុកាលនៃបទល្មើស បានកន្លងហួសទៅហើយ មុនពេលច្បាប់អវតកត្រូវបានអនុម័ត និងពន្យាអាជ្ញាយុកាលសម្រាប់ការចោទប្រកាន់បានដាក់ញត្តិ (Preliminary Objection Motion) នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង (Trial Chamber)។[3]

វាជាបញ្ហាផ្លូវច្បាប់អាចដេញដោលបាន (arguable case) ដែលអង្គនេះ សម្រេចយកមកពិចារណា។ មានហេតុផល និងមូលដ្ឋានផ្សេងៗ នៃគោលជំហរ ត្រូវបានលើកដោយភាគីទាំងពីរ (សហព្រះរាជអាជ្ញា និង មេធាវី) ព្រមទាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ។ ភាគីនិងចៅក្រម ឯកភាពថា រយៈពេលចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដែលមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យនៅកាន់អំណាច រយៈពេលនៃអាជ្ញាយុកាលសម្រាប់ចោទប្រកាន់មិនបានដើរទេ (Tolling) ដូចនេះ រយៈពេល១០ ឆ្នាំ ត្រូវរាប់គិតចាប់ពីឆ្នាំ១៩៧៩។[4] មានគោលជំហរពីរផ្ទុយគ្នាជាចម្បងក្នុងចំណោមមេធាវី ព្រះរាជអាជ្ញា ព្រមទាំងចៅក្រម។ ចៅក្រមអន្តរជាតិ និង មេធាវីយល់ស្របគ្នា ហើយសហព្រះរាជអាជ្ញានិងចៅក្រមជាតិមានទស្សនៈស្រដៀងគ្នាផងដែរ។

ចៅក្រមជាតិអះអាងថា រហូតដល់ឆ្នាំ១៩៩៨ ទើបប្រព័ន្ធយុត្តិធម៌កម្ពុជាមានដំណើរការពេញលេញ ដូចនេះរយៈពេល១០ឆ្នាំ ត្រូវរាប់ចាប់ពីឆ្នាំនេះ រហូតដល់ឆ្នាំ២០០៨ ទើបផុតអាជ្ញាយុកាល១០ឆ្នាំ។ ច្បាប់ អវតក ត្រូវអនុម័តក្នុងឆ្នាំ២០០៤ និងបានពន្យារយៈពេលអាជ្ញាយុកាលមុនឆ្នាំ២០០៨ មិនខុសច្បាប់ទេ។[5] បន្ថែមពីលើនេះ ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមិនបានរកឃើញថា ការពន្យាអាជ្ញាកាលនេះ ខុសនឹងរដ្ឋធម្មនុញ្ញឡើយ។[6]

[3] សំណុំរឿងលេខ ០០១, អញ្ញត្រកម្មបឋម ទាក់ទងនឹងការបញ្ចប់ការចោទប្រកាន់ បទល្មើសជាតិ E9/1 ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៩។

[4] សំណុំរឿងលេខ ០០១, អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចស្តីពី អញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ,E187,២៦ ខែកក្កដា ឆ្នាំ២០១០ កថាខ័ណ្ឌទី១៤។ខ្លឹមសារសម្រេចស្រដៀងគ្នានេះដែរ សូមមើលៈ សំណុំរឿង ០០២ អង្គជំនុំជម្រះ សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ), E122, ២២ ខែកញ្ញា ឆ្នាំ២០១១។

[5] E187, ដូចលេខយោងទី ៤, កថាខ័ណ្ឌ ២៥។

[6] E187, ដូចលេខយោងទី ៤, កថាខ័ណ្ឌ ៣៧។

ចៅក្រមអន្តរជាតិ យល់ផ្សេងពីនេះ ដោយអះអាងថា ប្រព័ន្ធយុត្តិធម៌កម្ពុជា មានដំណើរ អាចធ្វើការចោទប្រកាន់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ យ៉ាងហោចណាស់ក្នុងឆ្នាំ១៩៩៣។ រយៈពេល ១០ ឆ្នាំ ត្រូវបានបញ្ចប់ក្នុងឆ្នាំ២០០៣ មុនពេលដែលច្បាប់ អវតក បានអនុម័តក្នុង ឆ្នាំ២០០៤។ ចៅក្រមអន្តរជាតិបានធ្វើការអង្កេតលើការអនុវត្តរបស់ប្រទេសមួយចំនួន ហើយ រកឃើញថា ការពន្យារដែលមិនខុសច្បាប់ លុះត្រាតែធ្វើឡើងតាមរយៈច្បាប់របស់សភា និងនៅ មុនពេលដែលរយៈពេលនៃអាជ្ញាយុកាលមិនទាន់ផុតរលត់។[7] ចៅក្រមមិនបានអះអាងថា សេចក្តី សម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ខុស ឬយ៉ាងណាទេ ដោយគ្រាន់តែអះអាងថា ក្រុម ប្រឹក្សាធម្មនុញ្ញមិនបាននិយាយចំដល់បញ្ហាអាជ្ញាយុកាលនៃបទល្មើស និងថាសេចក្តីសម្រេច នេះមិនមែនជាច្បាប់របស់សភាទេ (Act of National Assembly)។[8] អាស្រ័យហេតុនេះ ការដែលតុលាការនៅបន្តចោទប្រកាន់បទល្មើសជាតិ អាចនាំឲ្យខុសពីគោលការណ៍អព្យាក្រឹត្យ ភាពរបស់ចៅក្រម (Impartiality of Judges)។ ...[9] ក្នុងន័យនេះ អវតក មិនអាចធ្វើការចោទ ប្រកាន់ខុចពីបទល្មើសជាតិ ការសម្លាប់ ឬការធ្វើទារុណកម្ម តាមក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ទេ ដោយសាររយៈពេលនៃចោទប្រកាន់ ១០ ឆ្នាំ បានកន្លងផុតទៅហើយ។

[7] E187, ដូចលេខយោងទី ៤, កថាខ័ណ្ឌ ៤៦-៣៨ និង ៥០។

[8] E187, ដូចលេខយោងទី ៤, កថាខ័ណ្ឌ ៤៣, ៤៧។

[9] ក្នុងលក្ខខណ្ឌទូទៅ ការហាមឃាត់មិនឲ្យមានការអនុវត្តប្រតិសកម្ម ចំពោះច្បាប់ព្រហ្មទណ្ឌគឺដើម្បី ការពារនូវតម្លៃនៃសុវត្ថិភាពគតិយុត្តិ និងធានារក្សាការអនុវត្តនូវគោលការណ៍អនាគតិ និងសត្យានុម័តរបស់នីតិរដ្ឋ។ ការបកស្រាយមាត្រា ៣ថ្មី នៃច្បាប់ អវតក ដែលអនុញ្ញាតឲ្យបង្កើតសាជាថ្មីនូវសិទ្ធិចោទប្រកាន់ចំពោះបទឧក្រិដ្ឋតាមច្បាប់ជាតិ លើបុគ្គលមួយចំនួនតូច ក្រោយពេលចិរវេលានៃអាជ្ញាយុកាលបានផុតរលត់អាចត្រូវបានគេយល់ឃើញថា ជាការរំលោភទៅលើគោលការណ៍ អនាគតិ និងសត្យានុម័ត (in general, the prohibition against the retroactive application of criminal law protects the values of legal certainty and safeguard the implementation of the principle of impartiality and objectivity by a State in accordance with the rule of law. An interpretation of Article 3 (new) of the ECCC Law allowing a reinstatement of the right to prosecute domestic crimes in relation to a limited number of individuals and after the expiry of statutory limitations may accordingly be perceived as an infringement of that duty of impartiality and objectivity) , E187, ដូចលេខយោងទី ៤, កថាខ័ណ្ឌ ៥៣។

ដោយសារ មិនអាចទទួលបានសំឡេង ៤ ក្នុងចំណោម ៥ (ចៅក្រមជាតិចំនួន ៣ និង អន្តរជាតិចំនួន ២) លើសេចក្តីសម្រេចញ្ញត្តិរបស់មេធាវីទទួលបានជ័យជំនះ។[10]

## ៣. កំណត់សំគាល់

សេចក្តីសម្រេច មានខ្លឹមសារសំខាន់គួរឲ្យចងចាំ និងដកស្រង់ ទោះបីបញ្ហាមួយចំនួនពាក់ព័ន្ធនឹងអាជ្ញាយុកាលមិនទាន់ត្រូវបានដោះស្រាយក្តី។ គេគួរចងចាំថា អាជ្ញាយុកាលមិនអនុវត្តចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិ (crimes under international law) ឡើយ ដូចជា បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ។[11] ពេលវេលានៃអាជ្ញាយុកាលនឹងផ្អាកដើរ ប្រសិនបើមាន "កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ"។[12] ដូចជា ការបើកការស៊ើបអង្កេតជាដើម ក៏ប៉ុន្តែខ្លឹមសារនៃ "កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ" មិនទាន់ត្រូវបានស្រាយបំភ្លឺទេ។ កាលណាកិច្ចមួយបានបន្តអាជ្ញាយុកាលនឹងគ្មានថ្ងៃបញ្ចប់ឡើយ ដែលមានន័យថា អយ្យការនៅតែអាចធ្វើការចោទប្រកាន់។ នេះវាអាចនឹងមានការបំពាននូវសិទ្ធិក្នុងការទទួលបានការវិនិច្ឆ័យសេចក្តីក្នុងពេលវេលាសមស្រប។[13] នេះមិនគិតដល់ការបាត់បង់ភស្តុតាង ហើយដែលនាំឲ្យសវនាការមិនមានភាពយុត្តិធម៌។[14]

ជាការអនុវត្តកន្លងមក ទោះបីមានច្បាប់ហាមឃាត់ក្តី[15] ក៏មានការចរចារក្រៅច្បាប់ដើម្បីបញ្ចប់បណ្តឹងព្រហ្មទណ្ឌ ដោយឲ្យជនល្មើសសងសំណងដល់ជនរងគ្រោះ។ ក្នុងន័យនេះ បណ្តឹងអាជ្ញានៅតែមានសុពលភាព ហើយការបន្តការចោទប្រកាន់អាចនៅតែធ្វើបាន។ បញ្ហាផ្លូវច្បាប់ដែលនឹងចោទឡើង ថាតើអាជ្ញាយុកាលចោទប្រកាន់បានផុតរលត់ហើយឬនៅ? វាមិនមែនជាសំណួរស្រួលៗ ទេក្នុងការរកចម្លើយ សម្រាប់មេធាវីពូកែពិត និងអ្នកសិក្សាស្រាវជ្រាវ។

---

[10] E187, ដូចលេខយោងទី ៤, កថាខ័ណ្ឌ ៥៦។ មាត្រា ១៤ (ថ្មី) នៃច្បាប់ស្តីពី អវតក, ក. សេចក្តីសម្រេច របស់អង្គជំនុំជម្រះ ទាមទារនូវសំឡេងគាំទ្រយ៉ាងតិចណាស់ចៅក្រម ៤រូប។

[11] ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មាត្រា ១៤៣។ អនុសញ្ញាស្តីពីការមិនអនុវត្តអាជ្ញាយុកាល ចំពោះបទឧក្រិដ្ឋកម្មសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឆ្នាំ ១៩៧០។

[12] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ មាត្រា ១១។

[13] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយឆ្នាំ ១៩៧៦ មាត្រា ១៤។

[14] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយឆ្នាំ ១៩៧៦ មាត្រា ១៤។

[15] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧ មាត្រា ២៥។

វាតម្រូវឲ្យមានការស្រាវជ្រាវស៊ីជម្រៅ លើសំណួរដែលបានចោទខាងលើ។ អ្វីដែលប្រសើរជាងនោះ គឺជាសេចក្តីណែនាំរបស់តុលាការកំពូលដែលជាស្ថាប័នកំពូលរបស់អង្គតុលាការ ដែលមានតួនាទី បំភ្លឺខ្លឹមសារច្បាប់មួយចំនួនជូនដល់ចៅក្រម។

សម្រាប់សេចក្តីសម្រេចទាំងស្រុង សូមទស្សនាទាញយក តាម www.eccc.gov.kh

# ផ្នែករដ្ឋប្បវេណី

# កំហុសដោយឡែក សំណង និង ការមិនទទួលខុសត្រូវក្នុង អំពើអនីត្យានុកូល

ដោយមេធាវី មាស បូរ៉ា*

## ១. សេចក្តីផ្តើម

ក្នុងពិភពលោកនេះ មានការបង្កកំហុសកើតមានឡើង ដែលកំហុសខ្លះកើតមានឡើងដោយសារអំពើមួយរបស់បុគ្គលតែម្នាក់ឯង។ ខណៈពេលខ្លះ ផលវិបាកបង្កដោយទង្វើរបស់មនុស្សជាច្រើន។ ដើម្បីដាក់ទោសបុគ្គលណាមួយ ក្នុងករណីខ្លះតម្រូវឲ្យមានការបង្ហាញពីចំណងហេតុ និងផល (linkage between cause and effect)។[16] អំពើមួយអាចចូលមកជ្រែកក្នុងទំនាក់ទំនងរវាងអំពើមួយ និងផលវិបាករបស់វា ដែលធ្វើឲ្យមានសំណួរថា៖ តើទង្វើបង្អាក់នេះចូលរួមនាំឲ្យមានផលវិបាកដែរឬទេ? ហើយប្រសិនបើមែន តើម្ចាស់ទង្វើនឹងទទួលខុសត្រូវ និងត្រូវសងក្នុងកម្រិតណា? អត្ថបទនេះ នឹងព្យាយាមបង្ហាញខ្លឹមសាររួមនៃប្រធានបទនេះ។

## ២. ខ្លឹមសារ

បុគ្គលម្នាក់ លើកដំបងវាយម្នាក់ទៀត នាំឲ្យបែកក្បាលចេញឈាម។ វាយជាអំពើដែលនាំឲ្យបែកក្បាលដែលជាផលវិបាកនៃអំពើ។ នេះមានតែទង្វើតែមួយគត់ និងងាយរកអ្នកដែលទទួលខុសត្រូវ។

គ្រោះថ្នាក់ចរាចរមួយបានកើតឡើង នាំឲ្យបុគ្គលបើកបរម៉ូតូម្នាក់របួសធ្ងន់ធ្ងរ។ ឡានសង្គ្រោះបន្ទាន់បានមកទទួល។ ដោយសារស្ទះចរាចរផង ឡានដឹកអ្នករបួស មានភាពយឺតយ៉ាវក្នុងការទៅដល់មន្ទីរពេទ្យ។ ក្រោមការពិនិត្យរបស់ពេទ្យធម្មតាប្រចាំការ១៥នាទី ក្រោយមកអ្នករងរបួសបានស្លាប់។ ក្នុងករណីនេះ មានគ្រោះថ្នាក់ចរាចរ (ទង្វើដំបូង) តែមិនទាន់បង្កឲ្យ

---

* អ្នកនិពន្ធជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈត្តករពាណិជ្ជកម្ម និងសាស្ត្រាចារ្យច្បាប់។

[16] David G. Owen, *the five elements of negligence*, 35 Hofstra Law Review, 2007, p.1673; *see* generally Paul J. Zwier, `*Cause in Fact' in Tort Law-A Philosophical and Historical Examination*, 31 (4) DePaul Law Review, 1982.

ស្លាប់ទេ។ បន្ថែមពីលើនេះ មានទង្វើរបស់ឡានសង្គ្រោះបន្ទាន់ស្នេះចរាចរ និងទង្វើរបស់ពេទ្យដែលចូលរួមជាផ្នែកនាំឲ្យជនរងគ្រោះស្លាប់។ ទង្វើខាងក្រោយទាំងនេះ ជាទង្វើបង្អាក់ (intervening act) ដែលនាំមានការផ្តាច់ចំណងទង្វើគ្រោះថ្នាក់ចរាចរ និងការស្លាប់។

ក្នុងន័យនេះ មានទង្វើជាច្រើនបានចូលរួមនាំឲ្យមានផលវិបាក។ តំណាងជនរងគ្រោះអាចប្តឹងអ្នកបង្ករហេតុទាំងអស់ ឲ្យពួកគេទទួលខុសត្រូវតាមចំណែកកំហុសនាំឲ្យមានការខូចខាតតាមទង្វើរៀងៗខ្លួន។

> *១. បើការខូចខាតបានកើតឡើង ដោយសារអំពើរបស់បុគ្គលច្រើននាក់រួមគ្នា អ្នកប្រព្រឹត្តអំពើបំពាននីមួយៗ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដោយសាមគ្គី។ ២. ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ ខាងលើនេះ ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពាននីមួយៗបានបញ្ជាក់អំពីភាគនៃអំពើដែលខ្លួនបានបង្កឲ្យមានការខូចខាត ជននោះត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតតាមសមាមាត្រ នៃភាគដែលខ្លួនបានបង្ក។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលទទួលស្គាល់ថា មានការសមគំនិត ឬមានទំនាក់ទំនងសហការយ៉ាងជិតស្និទ្ធក្នុងចំណោមអ្នកប្រព្រឹត្តអំពើបំពាន។ ៣. បើជនម្នាក់ក្នុងចំណោមអ្នកប្រព្រឹត្តអំពើអនីត្យានុកូលរួមបានសងការខូចខាតទាំងអស់ ដោយចេញចំណាយរបស់ខ្លួន ជននោះអាចទាមទារសំណងពីអ្នកផ្សេងទៀត ដែលប្រព្រឹត្តអំពើអនីត្យានុកូលរួមនោះបានតាមសមាមាត្រ នៃភាគដែលជនម្នាក់ៗបានបង្ក។*[17]

សាលដីកាតុលាការកំពូលមុនឆ្នាំ ២០០៩ ក៏បានអះអាងបញ្ជាក់ពីចំណែកទទួលខុសត្រូវក្នុងសំណង៖

> ១. *យល់ឃើញថា ការដែលតុលាការ* (ជាន់ទាប) *សំរេចដាក់បន្ទុកតែទៅលើជនជាប់ចោទដោយពុំពិចារណាអំពីកំហុសឆ្គងរបស់ជនរងគ្រោះផងនោះ* (អ្នកបើកម៉ូតូជាអនីតិជន បើកឌុបលើសចំណុះ និងពុំមានប័ណ្ណបើកបរ).. ទង្វើនេះ *ជាការរំលោភ ទៅនឹងមាត្រា ១០ និង មាត្រា ៣០ នៃច្បាប់ស្តីពីចរាចរជើងគោក... ដូច្នេះជនរងគ្រោះក៏ត្រូវរួមចំណែកក្នុងការទទួលខុសត្រូវ*

[17] ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០១១ មាត្រា ៧៥៤។

*អំពីព្យសនកម្មដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរនេះដែរ តាមមាត្រា ១៣២ នៃក្រិត្យច្បាប់លេខ៣៨ ក្រច។ ២. យល់ឃើញថា...ជនជាប់ចោទបើកបររថយន្តហុងដាអាគូរា ជ្រុលទៅបុកជនរងគ្រោះនោះ គឺបណ្តាលមកពីជនជាប់ចោទខ្វះការត្រួតពិនិត្យកង់រថយន្ត របស់ខ្លួនបណ្តាលអោយផ្ទុះកង់មុខទាញចង្កូតទៅបុកជនរងគ្រោះ។*[18]

បទប្បញ្ញត្តិនៃច្បាប់បានចែងឲ្យបុគ្គល (អ្នកប្រព្រឹត្ត)ទទួលខុសត្រូវ និងមេ ឬស្ថាប័នរបស់អ្នកប្រព្រឹត្ត អ្នកទទួលខុសត្រូវផងដែរ។ មាត្រា ៧៤៧ នៃក្រមនីតិរដ្ឋប្បវេណី បានចែងឲ្យនិយោជកទទួលខុសត្រូវចំពោះទង្វើរបស់និយោជិក។[19] និយោជកអាចជាបុគ្គល ឬជានីតិបុគ្គល (ក្រុមហ៊ុន)។[20] ចំណុចខាងក្រោយ បទប្បញ្ញត្តិដោយឡែកដែលមានអាចអនុវត្តចំពោះការទទួលខុសត្រូវរបស់នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ (មានកម្រិត)។[21]

ជាការឆ្លើយតបនឹងបណ្តឹង ភាគីចុងចម្លើយនីមួយៗដើម្បីរួចពីការទទួលខុសត្រូវអាចលើកយកការដោះសារ ដូចជាស្ថានភាពចាំបាច់ និងការការពារជាធម្មានុរូប[22]កម្រិតវិទ្យាសាស្ត្រនៃបច្ចេកទេសដែលមាននៅពេលផលិត (ការទទួលខុសត្រូវចំពោះផលិតផលរបស់អ្នកផលិតវត្ថុ)[23] ការត្រួតពិនិត្យដោយត្រឹមត្រូវ (ការទទួលខុសត្រូវរបស់និយោជក និងការទទួលខុសត្រូវ

---

[18]សាលដីកាតុលាការកំពូល សំណុំរឿងព្រហ្មទណ្ឌ សាលដីកាលេខ ២៩ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៨។

[19] មាត្រា ៧៤៧ ក្រមរដ្ឋប្បវេណីឆ្នាំ ២០១១។

[20] មាត្រា ៧៤៨ ក្រមរដ្ឋប្បវេណីឆ្នាំ ២០១១។ សម្រាប់កំហុសផ្នែកពេទ្យ (medical malpractice) វាអាចនាំឲ្យមានការទទួលខុសត្រូវរបស់មន្ទីរពេទ្យ។

[21] ក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ មាត្រា ៧៤៩។

[22] ក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ មាត្រា ៧៥៥។

[23] ក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ មាត្រា ២០១០ មាត្រា ៧៥១។ ១. *ក្នុងករណីដែលមានវិការៈនាំឲ្យមានគ្រោះថ្នាក់មិនសមហេតុក្នុងចលនវត្ថុដែលត្រូវបានផលិត ហើយបានបណ្តាល ឲ្យមានការខូចខាតដល់អ្នកដទៃដោយវិការៈនោះ ផលិតករនៃចលនវត្ថុនោះ ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតនោះ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយចំពោះករណីដែលមិនអាចប្រមាណនូវវិការៈនោះ តាមកម្រិតវិទ្យាសាស្ត្រ នៃបច្ចេកទេស ដែលមាននៅសម័យដែលផលិតនោះ។*

ចំពោះសំណង់ដែលជាប់នឹងដី)[24] ការទទួលយកគ្រោះថ្នាក់ពីសំណាក់ជនរងគ្រោះ[25] អសមត្ថភាពក្នុងការទទួលខុសត្រូវ។[26]

មូលហេតុនាំឲ្យមិនមានការទទួលខុសត្រូវខាងលើ មានចែងក្នុងក្រមរដ្ឋប្បវេណី។ ទោះបីជាយ៉ាងនេះក្តី មូលហេតុមួយចំនួនទៀតអាចត្រូវបានលើកយកមកសំអាងមុនតុលាការ ដើម្បីដោះសាររួចផុតពីការទទួលខុសត្រូវ។ អ្វីដែលសំខាន់ថាតើ ចៅក្រមយកមកពិចារណា ឬ មិនយក ដោយឈរលើមូលហេតុថា មិនមានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី គេគួរកត់សំគាល់ថា ក្រមរដ្ឋប្បវេណីកម្ពុជាមានប្រភពមកពីក្រមរដ្ឋប្បវេណីជប៉ុន ដែលចៅក្រមមួយចំនួននៅប្រទេសនេះ ហាក់ប្រកាន់នូវជំហរទូលាយស្រដៀងនឹងចៅក្រមប្រទេស Common Law ក្នុងការបកស្រាយច្បាប់។[27]

សម្រាប់ទង្វើទីមួយ (គ្រោះថ្នាក់ចរាចរ) ប្រសិនបើរបួសនេះ វាធ្ងន់ធ្ងរពេក ទោះបីជាមិនមានកត្តាបង្អាក់ ដូចជា ស្ទះចរាចរក្តីនាំឲ្យយឺតក្នុងការដឹកទៅមន្ទីរពេទ្យ ក៏អ្នករបួសនឹងស្លាប់តាមធម្មតា (natural course of dying) អ្នកបង្ករគ្រោះថ្នាក់ចរាចរនឹងទទួលខុសត្រូវចំពោះការស្លាប់តែឯង។[28] តុលាការកំពូលកម្ពុជាក៏ធ្លាប់បានថ្លែងមូលហេតុនេះដែរ៖

---

[24] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា ៧៤៧ និង ៧៥៣។ មាត្រា ៧៤៧ (២)៖ *បុគ្គលដែលស្ថិតក្នុងឋានៈ ត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជកត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ*។ មាត្រា ៧៥៣ (១)៖ *ក្នុងករណីដែលការសាងសង់សំណង់ដែលជាប់នឹងដី ឬការគ្រប់គ្រងសំណង់នោះមានវិការៈ ហើយបានបណ្តាលឲ្យមានការខូចខាតដល់អ្នកដទៃ អ្នកគ្រប់គ្រងសំណង់ និងកម្មសិទ្ធិករនៃសំណង់នោះត្រូវទទួលខុសត្រូវដោយសាមគ្គីក្នុងការសងការខូចខាតនោះ។ ប៉ុន្តែក្នុងករណីដែលអ្នកគ្រប់គ្រងបានបញ្ជាក់ថា ខ្លួនបានគ្រប់គ្រងដោយត្រឹមត្រូវអ្នកគ្រប់គ្រងនោះ អាចរួចផុតពីការផុតពីការទទួលខុសត្រូវបាន។*

[25] ក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ មាត្រា ៧៥៦។

[26] ក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ មាត្រា ៧៤៥។

[27] Craig P. Wagnild, *Civil Law Discovery in Japan: A Comparison of Japanese and U.S. Methods of Evidence Collection in Civil Litigation*, 3(1) Asian-Pacific Law & Policy Journal, 2002, p. 5. John O. Haley, *the Role of Courts in 'Making' Law in Japan: the Communitarian Conservatism of Japanese Judges*, Pacific Rim Law & Policy Journal Association, 2013, p.6.

[28] ឧទាហរណ៍ ការគាំងបេះដូង ជាការបង្កឲ្យស្លាប់តាមសភាពធម្មតា ( heart failure would be listed as having died from natural causes)។

*យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចអយ្យការអមតុលាការខេត្ត... ដែរ ដែលតម្កល់រឿងមរណៈភាពនៃកុមារទាំងពីរនាក់នេះ ពុំចាត់ការនោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះថា ពុំមានភស្តុតាងណាមួយបញ្ជាក់ថា មរណៈភាពនៃកុមារទាំងពីរជាមរណៈភាពតាមសភាវៈនៃអ្នកជំងឺ ឬ បណ្តាលមកពីការធ្វេសប្រហែសជាបទអាជ្ញារបស់អ្នកព្យាបាល ឬអាណាព្យាបាលឡើយ។*[29]

យុត្តិសាស្ត្រខ្លះបានយោងដល់ ភាពជិតនៃអំពើចំពោះផលវិបាក(proximate cause[30]) ដើម្បីកំណត់ថា អ្នកណាជាអ្នកទទួលខុសត្រូវ និងទទួលខុសត្រូវកម្រិតណា។ គ្រោះថ្នាក់ចរាចរបង្កឲ្យមនុស្សរងរបួសធ្ងន់ធ្ងរអាចបណ្តាលឲ្យស្លាប់ ប្រសិនបើមិនទទួលបានការសង្គ្រោះបន្ទាន់ជាហេតុបង្កក្នុងប្រភេទនេះ។ ការអះអាងថា ជនរងគ្រោះស្លាប់តាមធម្មតា ឬមិនមែន វាផ្អែកតាមឯកសារបញ្ជាក់របស់អ្នកជំនាញវិជ្ជាជីវៈពេទ្យ។

តំណាងជនរងគ្រោះអាចប្តឹងប្រឆាំងនឹងមន្ទីរពេទ្យ ដោយអះអាងថា ជនរងគ្រោះមិនទាន់ស្លាប់ទេ ហើយក៏នឹងមិនស្លាប់ដែរ ប្រសិនបើនាពេលមកដល់មន្ទីរពេទ្យភ្លាម គាត់ទទួលបានការសង្គ្រោះបន្ទាន់ពីវេជ្ជបណ្ឌិតជំនាញ។ មេធាវីរបស់មន្ទីរពេទ្យ ឬតំណាង អាចអះអាងថា ក្នុងករណីដូចគ្នានេះ និងស្ថានភាពនៃរបួសដូចគ្នា តាមទិន្និន័យ ឬបទពិសោធន៍ដ៏ច្រើនកន្លងមកជនរងគ្រោះក៏នៅតែស្លាប់ដែរ ទោះបីក្រោយពីទទួលបាននូវការសង្គ្រោះពីវេជ្ជបណ្ឌិតជំនាញភ្លាមៗក្តី។ វាក៏អាចមានការលើកឡើងនូវទ្រឹស្តីនៃការស្លាប់តាមធម្មតាដែរ។ នេះជាបញ្ហាពាក់ព័ន្ធនឹងភស្តុតាង និងកម្រិតភស្តុតាងដែលត្រូវបង្ហាញដើម្បីឲ្យចៅក្រមជឿបាន។

សម្រាប់ឡានសង្គ្រោះបន្ទាន់ ឬការស្ទះចរាចរ អំណះអំណាងស្រដៀងគ្នា ដើម្បីនាំឲ្យរួចពីការទទួលខុសត្រូវ ក៏អាចត្រូវបានលើកយកមកបញ្ជាក់ផងដែរ។ គេអាចអះអាងថា អ្នករងរបួស រងរបួសធ្ងន់ធ្ងរពេក។ បន្ថែមពីលើនេះ ចុងចម្លើយក៏អាចលើកថា កត្តាបង្អាក់ដែលចោទឡើង មិនជាប់ពាក់ព័ន្ធនឹងផលវិបាកនៃអំពើទេ។ ជាចុងក្រោយ កំហុសរបស់ជនរងគ្រោះ ក៏នឹងជាកត្តាមួយចូលរួមផងដែរ ក្នុងការសម្រេចថា អ្នកណាទទួលខុសត្រូវ និងទទួលខុសត្រូវកម្រិតណា ដូចខ្លឹមសារដកស្រង់ខាងលើបានបង្ហាញ។

[29] សាលដីកាតុលាការកំពូលលេខ ៨១ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥។

[30] Leon Green, *Contributory Negligence and Proximate Cause*, 1927, Faculty Scholarship Series. Paper 4457, http://digitalcommons.law.yale.edu/fss_papers/4457, p. 11.

## ៣. សង្ខេប

ទាំងទ្រឹស្តី និងច្បាប់បានចែងរួចហើយអំពីភាគនៃសំណង ចំពោះចំណែកខុសឆ្គងរបស់បុគ្គលណាមួយដែលចូលរួមខុស នាំឲ្យមានការខូចខាតដល់ជនរងគ្រោះ។ កំហុសរបស់ជនរងគ្រោះ ក៏នឹងត្រូវបានយកមកពិចារណាផងដែរ។ មានវិធានចំនួន២ ដែលគួរចងចាំ៖ ទី១. ផលវិបាកជាធម្មតាកើតឡើង ដោយសារអំពើដំបូងនៃអ្នកបង្កហេតុដំបូងដែលកត្តាបង្អាក់ ឬអន្តរាគមន៍មិនមែនជាកត្តាចម្បងទេ នាំឲ្យមានផលវិបាក និងទី២. អំពើបង្អាក់ត្រូវតែមានភាពពាក់ព័ន្ធទើបនាំឲ្យមានការទទួលខុសត្រូវ។

# មូលដ្ឋានក្នុងការបដិសេធការទទួលស្គាល់ និងអនុវត្ត មជ្ឈត្តវិនិច្ឆ័យបរទេស នៅក្នុងច្បាប់កម្ពុជា

ដោយមេធាវី គឹម សាន*

## ១. សេចក្តីផ្តើម

ការសម្រេចចិត្តរបស់គូភាគី ក្នុងការទទួលយកមជ្ឈត្តការបរទេសមិនចាំបាច់ទាក់ទងនឹងប្រាក់កាក់ ឬពេលវេលាទេ ប៉ុន្តែដោយសារមូលហេតុដែលគូភាគីត្រូវការឲ្យមាន *១.* ធ្វើការដោះស្រាយទំនាស់ក្នុងវេទិការមួយដែលមានតែមួយ ប្រកបដោយភាពឯករាជ្យ និងមិនលំអៀង និង *២.* ទទួលបានលទ្ធផលមួយដែលអាចយកទៅអនុវត្តបាននៅយុត្តាធិការដែលពាក់ព័ន្ធទាំងអស់។[31] ប្រទេសកម្ពុជាជារដ្ឋសមាជិកមួយនៃអនុសញ្ញាទីក្រុងញូយ៉ក[32]ដែលជាអនុសញ្ញាមួយផ្តល់ការគាំទ្រដល់ការអនុវត្តមជ្ឈត្តវិនិច្ឆ័យធ្វើឡើងនៅក្នុងមជ្ឈត្តការអន្តរជាតិ។ ប្រទេសជាសមាជិកទាំងអស់នៃអនុសញ្ញានេះ "ត្រូវទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យទាំងអស់ថា ចងកាតព្វកិច្ច និងត្រូវអនុវត្តមជ្ឈត្តវិនិច្ឆ័យទាំងនោះ ដោយអនុលោមតាម វិធាននីតិវិធីរបស់ដែនដីដែលមជ្ឈត្តវិនិច្ឆ័យត្រូវផ្អែកលើ"[33]។

លើសពីនេះទៀត មាត្រា ៣ នៃអនុសញ្ញានេះក៏បានតម្រូវមិនឲ្យរដ្ឋជាហត្ថលេខីដាក់លក្ខខណ្ឌតឹងតែងខ្លាំងនៅក្នុងការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យជាងលក្ខខណ្ឌដែលបានកំណត់ដោយអនុសញ្ញានេះ ឬកម្រៃ ឬបន្ទុកខ្ពស់នៅលើការទទួលស្គាល់ ឬការអនុវត្តមជ្ឈត្តវិនិច្ឆ័យក្នុងស្រុកឡើយ។ មាត្រានេះកំណត់ពីដែនកំណត់ដើម្បីការពារមិនឲ្យមានការទាត់ចោល

---

* មេធាវី **គឹម សាន** បានបញ្ចប់ថ្នាក់អនុបណ្ឌិត ផ្នែកច្បាប់សេដ្ឋកិច្ចអន្តរជាតិ ពីសកលវិទ្យាល័យ Victoria University of Wellington)VUW) ប្រទេសណូវែលហ្សេឡង់។ បច្ចុប្បន្នលោកក៏ជាបេក្ខជនមជ្ឈត្តករពាណិជ្ជកម្ម នៃមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ម.ជ.)។ លោក គឹម សាន ប្រកបវិជ្ជាជីវៈច្បាប់ដើម្បីកាត់បន្ថយឧបសគ្គនានាដែលធុរជនជួបប្រទះក្នុងធុរកិច្ចរបស់គាត់

[31] International Commercial Arbitration for Law Students (2nd Edition, Jeffrey Dasteel), Kindle Book, Loc 4500.

[32] អនុសញ្ញាទីក្រុងញូយ៉ក ស្តីពីការទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស ធ្វើឡើងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៥៨។ ប្រទេសកម្ពុជាបានទទួលស្គាល់ អនុសញ្ញាទីក្រុងញូយ៉ក នៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៦០ (www.treaties.un.org)។ អនុសញ្ញានេះមានសមាជិកចំនួន១៥០ប្រទេសជាងគិតមកត្រឹមឆ្នាំ២០១៨នេះ ។

[33] មាត្រា ៣ នៃអនុសញ្ញាទីក្រុងនីវ យ៉ក ១៩៥៨។

មជ្ឈត្តវិនិច្ឆ័យបរទេស តាមរូបភាពបង្កើតទម្រង់ទទួលស្គាល់ ឬទម្រង់អនុវត្ត ដោយការណែនាំឲ្យប្រើស្តង់ដារតែមួយរវាងមជ្ឈត្តវិនិច្ឆ័យជាតិ និងអន្តរជាតិ។ យើងពិនិត្យឃើញថា ក្រមនីតិវិធីរដ្ឋប្បវេណីបានព្យាយាមសម្របសម្រួលដើម្បីសម្រេចគោលបំណងនៃមាត្រា ៣ នៃអនុសញ្ញានេះ ដែលតម្រូវមិនឲ្យរដ្ឋជាហត្ថលេខីដាក់ល័ក្ខខ័ណ្ឌតឹងតែងពេកលើការទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស ជាងការអនុវត្តមជ្ឈត្តវិនិច្ឆ័យក្នុងស្រុក។ ច្បាប់ចែងពីនីតិវិធីអនុវត្តរបស់ប្រទេសកម្ពុជាបានកំណត់ពីល័ក្ខខ័ណ្ឌទម្រង់មួយចំនួន ដើម្បីទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យមួយដើម្បីការអនុវត្ត រួមមាន ១. ច្បាប់ដើម នៃសេចក្តីសម្រេចមជ្ឈត្តករ ដែលត្រូវបានបញ្ជាក់ដោយត្រឹមត្រូវ.២. ច្បាប់ដើមនៃកិច្ចសន្យាមជ្ឈត្តកម្ម ឬឯកសារចម្លងនៃកិច្ចសន្យានោះ ដែលមានសេចក្តីបញ្ជាក់ត្រឹមត្រូវ។[34] បើសិនជាសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស ឬកិច្ចសន្យាពុំមានជាភាសាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាទេ ភាគីដែលស្នើត្រូវតែផ្តល់ការបកប្រែដែលមានការបញ្ជាក់ត្រឹមត្រូវ។[35] ការបកប្រែដែលមានការបញ្ជាក់ត្រឹមត្រូវនេះមិនបានតម្រូវថាជាការបកប្រែត្រូវធ្វើឡើងដោយមន្ទីរសាការី ឬក្រុមហ៊ុនបកប្រែសុទ្ធសាធ ឬអ្នកបកប្រែឯកជននោះទេ។ ប្រទេសកម្ពុជាពុំទាន់មានច្បាប់ ឬវិធានទាក់ទងនឹងការទទួលស្គាល់អ្នកបកប្រែផ្លូវការ រួមទាំងអ្នកបកប្រែការងារតុលាការនៅឡើយទេ។ ការបកប្រែ និងបញ្ជាក់ដោយបុគ្គលឯកជនអាចស្ថិតនៅក្នុងភាពមិនច្បាស់លាស់ ថាតុលាការត្រូវទទួលស្គាល់ឬទេ។

ទោះបីជាការយល់ព្រមទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសជាទម្លាប់ (Norms) ជាជាងការលើកលែង(Exception)ដែលមានបញ្ញត្តិនៅក្នុងមាត្រា៣ នៃអនុសញ្ញាទីក្រុងញូយ៉កក្របខ័ណ្ឌច្បាប់ជាតិ នៃប្រទេសកម្ពុជាមានការឯកភាពទាំងស្រុងជាមួយនឹងមាត្រា៥ នៃអនុ-សញ្ញានេះ ស្តីពីល័ក្ខខ័ណ្ឌដែលតុលាការអនុវត្ត (ដែលក្នុងករណីនេះជាតុលាការនៃប្រទេសកម្ពុជា) អាចបដិសេធមិនទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យដែលបានសម្រេចហើយនៅបរទេស។

[34] មាត្រា ៣៥៣.២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមាត្រា ៧ នៃច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស

[35] មាត្រា ៧ នៃច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញា

## ២. មូលដ្ឋានដើម្បីបដិសេធការទទួលស្គាល់ ឬ/និងការប្រតិបត្តិ[36]

ការបដិសេធមិនទទួលស្គាល់ ឬអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសទាក់ទងនឹងស្ថាប័នដែលមានសមត្ថកិច្ចអនុវត្ត ក្នុងស្រុកដែលទ្រព្យសម្បត្តិរបស់ភាគីចាញ់ក្តីស្ថិតនៅច្បាប់នីតិវិធីដែលមានចែងពីមូលហេតុនៃការបដិសេធនោះ និងត្រូវមានការស្នើបដិសេធរបស់ភាគីដែលនឹងទទួលការខូចខាតផលប្រយោជន៍ពីការអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ ដោយឡែក តុលាការអនុវត្តអាចបដិសេធមិនអនុវត្ត មជ្ឈត្តវិនិច្ឆ័យបរទេសដោយមិនមានការស្នើសុំ ដោយមូលហេតុវិវាទនៃមជ្ឈត្តវិនិច្ឆ័យបរទេសនោះ មិនមែនជាវិវាទផ្នែកពាណិជ្ជកម្ម ឬការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសនោះបំពានលើសណ្តាប់ធ្នាប់សាធារណៈរបស់ប្រទេសដែលតុលាការអនុវត្តតាំងនៅ។

ទាក់ទងនឹងស្ថាប័នអនុវត្តសាលាឧទ្ធរណ៍ នៃប្រទេសកម្ពុជាមានសមត្ថកិច្ចក្នុងការទទួលការប្តឹងជំទាស់ ទទួលស្គាល់ និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស[37] នៅក្នុងខណៈដែលតុលាការកំពូលមានសមត្ថកិច្ចក្នុងការធ្វើការពិនិត្យចុងក្រោយ ដែលមានសមត្ថកិច្ចជំនុំជម្រះ លើបណ្តឹងជំទាស់របស់ភាគីវិវាទដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍[38]។ មាត្រា ៣៥៣(៧) នៃក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ល័ក្ខខ័ណ្ឌដែលតុលាការអាចធ្វើការត្រួតពិនិត្យបានយ៉ាងទូលំទូលាយ ដោយប្រើប្រាស់វិធាននីតិវិធីដើម្បីបដិសេធការអនុវត្តមជ្ឈត្តវិនិច្ឆ័យដូចជា[39]៖

១. ការសម្រេចពីមោឃភាពនៃកិច្ចសន្យាមជ្ឈត្តកម្ម (ឬខ នៃមជ្ឈត្តកម្ម)

២. វិវាទមិនមែនពាណិជ្ជកម្ម ឬ ˝វិវាទក្រៅទំហំនៃចំណុចនេះ˝ ឬ ˝មានសេចក្តីសម្រេចអំពីចំណុចដែលហួសពីទំហំ នៃចំណុចដែលត្រូវទទួលមជ្ឈត្តកម្ម˝

[36] យើងសង្កេតឃើញមានការប្រើពាក្យ ˝អនុវត្ត˝ ខុសគ្នា រវាងច្បាប់មួយចំនួនទាក់ទងនឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ នៃប្រទេសកម្ពុជា។ ពាក្យ˝អនុវត្ត˝ ត្រូវបានប្រើនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដោយឡែក ពាក្យ ˝ប្រតិបត្តិ˝ ត្រូវបានប្រើនៅក្នុងច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស អនុម័តនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១។

[37] យោងតាមមាត្រា ៣៥៣.២ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍មានសមត្ថកិច្ចសម្រេចលើពាក្យសុំចេញដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបរទេស។ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មាត្រា ៤២។

[38] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មាត្រា ៤៣។

[39] មាត្រា ១៥ នៃច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ក៏មានចែងមូលដ្ឋានដូចគ្នាទៅនឹងក្រមនីតិវិធីរដ្ឋប្បវេណីដែរ ក្នុងការបដិសេធមិនទទួលស្គាល់ និងការប្រតិបត្តិ (អនុវត្ត) មជ្ឈត្តវិនិច្ឆ័យបរទេស។

៣. នីតិវិធីចាប់ផ្ដើមមជ្ឈត្តកម្មមិនសមស្រប ឬសេចក្ដីជូនដំណឹងអំពីការជ្រើសតាំងមជ្ឈត្តករមិនបានធ្វើឡើងសមរម្យ ឬមិនអាចការពារខ្លួនដោយសារមូលហេតុផ្សេងទៀត

៤. វេទិការមជ្ឈត្តការ ឬនីតិវិធី នៃមជ្ឈត្តការមិនស្របតាមការព្រមព្រៀងរបស់ភាគី ឬមិនស្របតាមបទដ្ឋានគតិយុត្ត នៃប្រទេសដែលមជ្ឈត្តកម្មត្រូវបានធ្វើឡើង។

៥. មជ្ឈត្តវិនិច្ឆ័យដែលមិនទាន់មានអនុភាព ចងកាតព្វកិច្ចរបស់គូភាគី ឬត្រូវបានលុបចោលដោយតុលាការនៃប្រទេស ដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានចេញ។

### *១. មោឃភាពនៃកិច្ចសន្យាមជ្ឈត្តកម្ម*

ជាតួយ៉ាងមាត្រា ៣៥៣.៣.ក នៃក្រមនីតិវិធីរដ្ឋប្បវេណីអនុញ្ញាតឲ្យតុលាការប្រើហេតុផលដែលភាគីស្នើសុំបានស្នើឡើង ក្នុងការបដិសេធការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ដើម្បីសម្រេចពីមោឃភាពនៃកិច្ចសន្យាមជ្ឈត្តកម្ម (ឬខ នៃមជ្ឈត្តកម្ម) តាមបទដ្ឋានគតិយុត្តដែលភាគីបានរួមគ្នាកំណត់ជាច្បាប់យោង ឬតាមបទដ្ឋានគតិយុត្ត នៃប្រទេសដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានធ្វើឡើង[40]។ ជាធម្មតាមានស្ថានភាពពីរដើម្បីបដិសេធ ដែលមានចែងនៅក្នុងមាត្រា ៥ (១)(ក) នៃអនុសញ្ញា គឺ (១). មានអសមត្ថភាពរបស់ភាគី ឬ (២). កិច្ចព្រមព្រៀងនោះគ្មានសុពលភាព ដែលមានចែងក្នុងច្បាប់របស់គូភាគី ឬដែលមានចែងក្នុងច្បាប់របស់ប្រទេសដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានធ្វើឡើង ប្រសិនបើគូភាគីមិនបានជ្រើសរើសច្បាប់គ្រប់គ្រងលើកិច្ចព្រមព្រៀងនោះ។ ដូច្នេះ ប្រសិនបើគូភាគីបានជ្រើសរើសគ្រប់គ្រងកិច្ចព្រមព្រៀងតាមច្បាប់កម្ពុជា បទដ្ឋានក្នុងការវាយតម្លៃពីមោឃភាពត្រូវកំណត់ដោយបញ្ញត្តិនានារបស់ច្បាប់កម្ពុជា។ មាត្រា៣៥៧ នៃក្រមរដ្ឋប្បវេណី ចែងពីអត្ថន័យនៃពាក្យ "មោឃភាព" កិច្ចព្រមព្រៀង ថាធ្វើឡើងបានទៅលើកិច្ចព្រមព្រៀងមួយដែលផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។ មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណីអាចត្រូវយកមកប្រើប្រាស់ដើម្បីវាយតម្លៃសិទ្ធិជាតំណាងស្របច្បាប់របស់បុគ្គល ដែលចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះថាតើមានសិទ្ធិពេញលេញ ឬបានទទួលសិទ្ធិប្រទានពីក្រុមហ៊ុនរបស់ខ្លួនឬទេ។

[40] មាត្រា ៣៥៣.១.ក នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ២. វិវាទមិនមែនពាណិជ្ជកម្ម

ទន្ទឹមនឹងនោះដែរ តុលាការអាចបដិសេធមិនអនុវត្ត សេចក្តីសម្រេចមជ្ឈត្តករ (មជ្ឈត្តវិនិច្ឆ័យ)ទាក់ទងនឹងវិវាទមិនមែនពាណិជ្ជកម្ម ឬ "វិវាទក្រៅទំហំនៃចំនុចនេះ" ឬ "មានសេចក្តីសម្រេចអំពីចំណុចដែលហួសពីទំហំ នៃចំណុចដែលត្រូវទទួលមជ្ឈត្តកម្ម"។[41] នៅពេលដែលច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនបានកំណត់ពីអ្វីទៅដែលហៅថា វិវាទ "មិនមែនពាណិជ្ជកម្ម" គេអាចស្វែងយល់ពីពាក្យ "មិនមែនពាណិជ្ជកម្ម" ដោយយល់ដឹងមាត្រា ២ (ឈ) នៃច្បាប់នេះដែលផ្តល់ការណែនាំ ពីសញ្ញាណទំនាស់ពាណិជ្ជកម្ម។[42] ជាឧទាហរណ៍ទំនាស់មិនមែនពាណិជ្ជកម្មអាចមានរួមទាំងទំនាស់លើការគ្រប់គ្រងកូន រឿងព្រហ្មទណ្ឌ ក្ស័យធន សុពលភាពនៃពាណិជ្ជនាម ឬប៉ាតង់ និងទំនាស់ដទៃទៀតដែលធ្វើឲ្យប៉ះពាល់ដល់តតិយជន ឬមានផលប៉ះពាល់ខ្លះដល់សណ្តាប់ធ្នាប់សាធារណៈ។[43] គួរកត់សម្គាល់ថា ការកំណត់ថា វិវាទមួយជាវិវាទពាណិជ្ជកម្ម ឬទេ ជាតួយ៉ាងតែងតែត្រូវបានសម្រេចរួចហើយ ចាប់តាំងពីពេលទទួលរឿងក្តីនោះ នៅប្រទេសមួយទៀតដែលមជ្ឈត្តការបានធ្វើឡើង។

## ៣. ខ្វះការជូនដំណឹង ឬយុត្តិធម៌

ច្បាប់ជាតិ នៃប្រទេសកម្ពុជា ក៏អនុញ្ញាតឲ្យតុលាការសម្រេចបដិសេធលើមជ្ឈត្តវិនិច្ឆ័យដែលនីតិវិធីចាប់ផ្តើមមជ្ឈត្តកម្មមិនសមស្រប ឬសេចក្តីជូនដំណឹងអំពីការជ្រើសតាំងមជ្ឈត្តករមិនបានធ្វើឡើងសមរម្យ ឬមិនអាចការពារខ្លួនដោយសារមូលហេតុផ្សេងទៀត។[44]

---

[41] មាត្រា ៣៥៣.៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[42] មាត្រា ២ (ឈ)នៃច្បាប់ ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម កំណត់ថា ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានជាជាទី៖ កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬការផ្លាស់ប្តូរទំនិញ ឬសេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬទីភ្នាក់ងារពាណិជ្ជកម្ម ការទិញលក់គណនីក្រុមហ៊ុន ការជួលទីតាំង ឬសម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទានក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀត នៃសហប្រតិបត្តិការឧស្សាហកម្ម ឬពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក។ "

[43] The Principles and Practice of International Commercial Arbitration, Margaret L. Moses, 2008, Cambridge University Press, ទំព័រ ២១៦

[44] មាត្រា ៣៥៣.៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

មាត្រា៥.ខ នៃអនុសញ្ញាទីក្រុងញូយ៉ក បានកំណត់ល័ក្ខខ័ណ្ឌបដិសេធស្របគ្នានឹងច្បាប់ជាតិស្តីពីការជូនដំណឹងមិនសមស្របរួមមាន ទាំងការតែងតាំងមជ្ឈត្តករ ក៏ដូចជាអំពីនីតិវិធីមជ្ឈត្តកម្មផងដែរ។ លើសពីនេះមាត្រា១៥.២ នៃច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិបានសម្របតាមមាត្រា ៥.ខ នៃអនុសញ្ញាទីក្រុងញូយ៉ក ដោយផ្តល់ឲ្យតុលាការនូវអំណាចបដិសេធមជ្ឈត្តវិនិច្ឆ័យ ផ្អែកលើហេតុផលដែលថា ភាគីម្ខាងទៀតមិនបានផ្តល់នូវឱកាសចូលរួមតវ៉ាក្តី។ ជាទូទៅតុលាការអនុវត្តមិនព្យាយាមធ្វើការវាយតម្លៃឡើងវិញពីការដោះស្រាយបញ្ហាទទួលយកភស្តុតាងបង្ហាញនៅមជ្ឈត្តកម្ម ឬលើដែនកំណត់លើចំនួនសាក្សី ឬទំហំនៃសាក្ខីកម្មរបស់សាក្សីទាំងឡាយ។ ប៉ុន្តែប្រសិនរបៀបដែលឈានដល់ការចេញសេចក្តីសម្រេចរបស់មជ្ឈត្តកម្មលើរឿងក្តីមួយ ត្រូវបានមើលឃើញថា ប៉ះពាល់ដល់ការផ្តល់យុត្តិធម៌យ៉ាងសំខាន់ នោះអាចធ្វើឲ្យតុលាការអនុវត្តមួយយល់ថាការសម្រេចនៅមជ្ឈត្តកម្មបានបដិសេធគោលការណ៍ស្មើភាពគ្នានៅចំពោះមុខច្បាប់។[45]

ដោយឡែក ឃ្លាដែលរៀបរាប់ថា "មិនអាចការពារខ្លួនដោយសារមូលហេតុផ្សេងទៀត" នៃមាត្រា៣៥៣.៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីជាឧទាហរណ៍ មិនបានបង្កើតឲ្យមានជាស្តង់ដារសម្រាប់បកស្រាយមួយច្បាស់លាស់ទេ ប៉ុន្តែនឹងបើកផ្លូវឲ្យមានការពិនិត្យពីតុលាការយ៉ាងទូលំទូលាយថាតើមានការបំពាន ឬបដិសេធគោលការណ៍ស្មើភាពគ្នានៅចំពោះមុខច្បាប់ ឬទេ? ក្នុងពេលទន្ទឹមគ្នានេះ មាត្រា ១៥.២ នៃច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិមិនបានចែងពីមូលហេតុការពារផ្សេងទៀត ដូចដែលមាត្រា ៣៥៣.៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ។ ហេតុផលខុសគ្នានេះអាចធ្វើឲ្យតុលាការយល់ខុសគ្នាក្នុងការប្រើអំណាចត្រួតពិនិត្យរបស់ខ្លួន ដើម្បីសម្រេចថាត្រូវបដិសេធមជ្ឈត្តវិនិច្ឆ័យបរទេស។

### *៤. វេទិកា ឬនីតិវិធី នៃមជ្ឈត្តការ មិនស្របតាមការព្រមព្រៀងរបស់ភាគី*

តុលាការក៏អាចសម្រេចមិនទទួលស្គាល់ ឬប្រតិបត្តិមជ្ឈត្តវិនិច្ឆ័យ ផ្អែកលើហេតុផលនៃកំហុសពីការបង្កើតវេទិការមជ្ឈត្តការ ឬនីតិវិធីប្រើក្នុងមជ្ឈត្តការនោះមិនបានស្របទៅនឹងបញ្ញត្តិដែលគូភាគីបានព្រមព្រៀងគ្នា បន្ទាប់ពីភាគីដែលនឹងខាតប្រយោជន៍បង្ហាញពីភស្តុតាងពី

[45] The Principles and Practice of International Commercial Arbitration, Margaret L. Moses, 2008, Cambridge University Press, ទំព័រ ២១១

កំហុសនោះ។ ក្នុងករណីដែលភាគីមិនមានការព្រមព្រៀងជាមុនទេ មជ្ឈត្តវិនិច្ឆ័យមួយអាចមិនត្រូវទទួលស្គាល់ និងប្រតិបត្តិដោយផ្អែកលើហេតុផលដែលផ្ទុយនឹងច្បាប់នៃប្រទេសដែលត្រូវបានធ្វើវេទិការមជ្ឈត្តការនោះ(lex arbitri)។[46] តុលាការត្រូវបកស្រាយទ្រឹស្តី"នីតិវិធីមជ្ឈត្តការ" ក្នុងន័យទូលាយ ដោយរួមបញ្ចូលស្ថានភាពដែលកើតឡើងចាប់តាំងពីពេលដែលមានសំណើធ្វើមជ្ឈត្តការរហូតដល់នីតិវិធីក្រោយពេលចេញមជ្ឈត្តវិនិច្ឆ័យ។[47] ដោយហេតុថាការបកស្រាយក្នុងន័យចង្អៀត និងធ្វើឲ្យការបដិសេធមិនទទួលស្គាល់ ឬអនុវត្តមានភាពផុយស្រួយពេកជាហេតុធ្វើឲ្យប៉ះពាល់ដល់ដំណើរការមជ្ឈត្តការ និងតម្លៃនៃមជ្ឈត្តវិនិច្ឆ័យដែលជាផ្លែផ្ការបស់ដំណើរការនោះ។

### *៥. មជ្ឈត្តវិនិច្ឆ័យដែលមិនទាន់មានអនុភាព ចងកាតព្វកិច្ចរបស់គូភាគី ឬត្រូវបាន លុបចោល ដោយតុលាការនៃប្រទេស ដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានចេញ*

អនុលោមតាមមាត្រា ៥.១.ង នៃអនុសញ្ញាទីក្រុងញូយ៉ក មជ្ឈត្តវិនិច្ឆ័យមួយមិនអាចអនុវត្តបានទេ លើកលែងតែមជ្ឈត្តវិនិច្ឆ័យនោះបានចងកាតព្វកិច្ចរបស់គូភាគី។ ទោះបីជាពាក្យ"ចងកាតព្វកិច្ច" មិនមានពន្យល់នៅក្នុងអនុសញ្ញាក៏ដូចជានៅក្នុងច្បាប់ខ្មែរពាក់ព័ន្ធនឹងមជ្ឈត្ត-ការពាណិជ្ជកម្ម ពាក្យនេះត្រូវបានគេយល់ជាទូទៅថា រឿងអង្គសេចក្តីបានចប់សព្វគ្រប់ហើយ និងឧទ្ធរណ៍លើរឿងដដែលមិនអាចធ្វើឡើងទេ។ នៅពេលដែលតុលាការអនុវត្តទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យមួយថា មានសុពលភាព និងចងកាតព្វកិច្ច មជ្ឈត្តវិនិឆ្ឆ័យនោះមានតម្លៃស្មើនឹងសាលក្រមរបស់តុលាការអនុវត្តនោះ។[48] ដោយសារមជ្ឈត្តវិនិឆ្ឆ័យមានឋានៈពេញលេញផ្លូវការតាមច្បាប់ បញ្ហាទាំងឡាយដែលបានសម្រេចរួចហើយដោយមជ្ឈត្តវិនិច្ឆ័យ ជារឿយៗមិនអាចធ្វើការប្តឹង ឬធ្វើមជ្ឈត្តវិនិច្ឆ័យឡើងវិញទេ។[49]

ម៉្យាងវិញទៀត អនុលោមតាមមាត្រា ៥.១.ង នៃអនុសញ្ញាទីក្រុងញូយ៉ក ដដែលបានចែងថា តុលាការអាចអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសមួយបាន នៅពេលដែលមជ្ឈត្តវិនិច្ឆ័យនោះ

---

[46] មាត្រា ៥.១.ឃ នៃ អនុសញ្ញាទីក្រុង ញូវ យ៉ក

[47] Jarvin, S. "Irregularity in the Composition of the Arbitral Tribunal and the Procedure." In: Gaillard, E. and D. DiPietro (eds.) Enforcement of Arbitration Agreements and International Arbitral Awards. Cameron (May 2008), p. 730. ISBN 13:9781905017472.

[48] The Principles and Practice of International Commercial Arbitration, Margaret L. Moses, 2008, Cambridge University Press, ទំព័រ ២០៣

[49] Gary Born, International Commercial Arbitration, 916 (2001).

មិនត្រូវបានជំទាស់ ឬលុបចោលដោយស្ថាប័នមានសមត្ថកិច្ចដែលបានចេញមជ្ឈត្តវិនិច្ឆ័យនោះ។ យោងតាមសន្ធិសញ្ញាទីក្រុងញូយ៉ក ក៏ដូចជាច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិរបស់កម្ពុជា តុលាការអនុវត្តក្នុងប្រទេសកម្ពុជាមានអំណាចក្នុងការទទួលស្គាល់ ឬអនុវត្តមជ្ឈត្តវិនិច្ឆ័យ តែមិនមានអំណាចក្នុងការលុបចោលមជ្ឈត្តវិនិច្ឆ័យនោះទេ។ ដូច្នេះ ភាគីដែលនឹងបាត់បង់ប្រយោជន៍ដែលចង់លុបចោលមជ្ឈត្តវិនិច្ឆ័យ ត្រូវដាក់ពាក្យមកតុលាការដែលបានសម្រេចចេញមជ្ឈត្តវិនិច្ឆ័យ។ ចំណែកភាគីដែលឈ្នះដែលចង់អនុវត្តមជ្ឈត្តវិនិច្ឆ័យត្រូវដាក់ពាក្យទៅតុលាការ ដែលទ្រព្យសម្បត្តិរបស់ភាគីដែលនឹងបាត់បង់ប្រយោជន៍ (ភាគីចាញ់) តាំងនៅ។[50]

ទោះបីជាចំនុចទាំង ៥ ខាងលើទាមទារឲ្យមានការសំអាងបញ្ជាក់ដោយបង្ហាញភស្តុតាងពីភាគីដែលនឹងទទួលការខូចខាតប្រយោជន៍ជាមុន[51]ក៏ដោយ លក្ខខ័ណ្ឌនេះរឹតតែផ្តល់ហេតុផលឲ្យតុលាការអនុវត្តធ្វើអន្តរាគមន៍ស៊ីជម្រៅ ក្នុងការវែកញែកលក្ខខ័ណ្ឌនីតិវិធីនៃមជ្ឈត្តវិនិច្ឆ័យក្នុងក្របខ័ណ្ឌច្បាប់ក្នុងប្រទេសកម្ពុជា។ ដោយឡែកចំណុចខាងក្រោម សម្គាល់អំពីអំណាចធ្វើការសម្រេចឡើងវិញដោយផ្ទាល់មុខ[52]ដើម្បីបដិសេធការអនុវត្តសេចក្តីសម្រេចមជ្ឈត្តការ តាមការយល់ឃើញរបស់តុលាការអនុវត្តដូចតទៅ[53]៖

១. ចំណុចដែលជាកម្មវត្ថុនៃវិវាទ មិនអាចដោះស្រាយបាន ដោយមជ្ឈត្តកម្ម។

២. ការទទួលស្គាល់ ឬ ការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ។

### ១. ចំណុចវិវាទមិនអាចដោះស្រាយបានដោយមជ្ឈត្តកម្ម

ដោយហេតុថាមាត្រា១ នៃអនុសញ្ញាទីក្រុងញូយ៉ក បានអនុញ្ញាតឲ្យរដ្ឋនីមួយៗ រួមទាំងកម្ពុជាអនុវត្តតាមអនុសញ្ញាលើកម្មវត្ថុនៃទំនាស់ពាណិជ្ជកម្ម ប៉ុន្តែទុកចំណុចខុសៗគ្នាដែលត្រូវចាត់ទុកថា "ពាណិជ្ជកម្ម" ឲ្យប្រែប្រួលតាមបទដ្ឋានត្រួតពិនិត្យរបស់ច្បាប់ជាតិដែលទាមទារឲ្យ

[50] The Principles and Practice of International Commercial Arbitration, Margaret L. Moses, 2008, Cambridge University Press, ទំព័រ ២១៣

[51] មាត្រា ៣៥៣.៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[52] ដោយមិនចាំបាច់មានការសំអាងបញ្ជាក់អំពីហេតុទាំងឡាយមាននៅក្នុងចំណុច ក ដល់ខ នៃមាត្រា ៣៥៣.៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពីភាគីដែលនឹងទទួលការខូចខាតផលប្រយោជន៍។

[53] មាត្រា ៣៥៣.៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

មានការពិនិត្យបកស្រាយយ៉ាងទូលំទូលាយ។[54] ស្ថានភាពនេះ ទាក់ទងនឹងគោលការណ៍នីត្យានុកូលដែលកំណត់ថា ចំណុចវិវាទមួយត្រូវមានច្បាប់ចែងថាមិនអាចត្រូវដោះស្រាយ ដោយមជ្ឈត្តកម្ម។ ច្បាប់របស់ប្រទេសកម្ពុជាមិនមានចែងពីចំណុចដែលមិនអាចដោះស្រាយបានដោយវេទិការមជ្ឈត្តកម្មទេ តែមានចែងពីអត្ថន័យនៃទំនាក់ទំនងពាណិជ្ជកម្ម នៅក្នុងមាត្រា២ (ឈ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ គេអាចធ្វើការកត់សម្គាល់ថា ច្បាប់ស្តីពីមជ្ឈត្ត-ការផ្នែកពាណិជ្ជកម្ម ធ្វើឡើងដើម្បីដោះស្រាយទំនាស់ពាណិជ្ជកម្ម និងស្របតាមការស្ម័គ្រចិត្តរបស់ភាគីវិវាទ។[55]

ដោយឡែកចំពោះទំនាស់ដទៃទៀត ដែលមិនស្ថិតនៅក្នុងដែនកំណត់នៃទំនាស់ពាណិជ្ជកម្ម និងស្របតាមគោលការណ៍ស្ម័គ្រចិត្តទេ នឹងត្រូវដោះស្រាយដោយស្ថាប័នមានសមត្ថកិច្ចមិនមែនមជ្ឈត្តកម្ម។ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនមានអនុភាពផ្លូវច្បាប់ លើច្បាប់នានាដទៃទៀត ដែលគ្រប់គ្រងទំនាស់ពាណិជ្ជកម្មដែលគ្មានការស្ម័គ្រចិត្តរបស់ភាគីអំពីសមត្ថកិច្ចដែលគេចង់ឲ្យដោះស្រាយ និងច្បាប់ដែលគ្រប់គ្រងទំនាស់មិនមែនពាណិជ្ជកម្មទេ។[56]

តុលាការអនុវត្តដែលត្រួតពិនិត្យមជ្ឈត្តវិនិច្ឆ័យ អាចពិនិត្យមើលថាតើវេទិការមជ្ឈត្តកម្មបរទេសបានដោះស្រាយទំនាស់របស់ភាគីឬទេ ឬបានសម្រេចពីលទ្ធផលមួយដែលបានប៉ះពាល់ដល់ប្រយោជន៍របស់តតីយជនឬទេ។[57]

## ២. សណ្តាប់ធ្នាប់សាធារណៈ

មាត្រា ៥ (២) (ខ) នៃអនុសញ្ញាទីក្រុងញូយ៉កពន្យល់ថា ការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យអាចត្រូវបានជំទាស់ ប្រសិនបើតុលាការរកឃើញថា ការទទួលស្គាល់ ឬការអនុវត្តមជ្ឈត្តវិនិច្ឆ័យផ្ទុយនឹងគោលនយោបាយសាធារណៈរបស់ប្រទេសនោះ។ ទោះបីជាយ៉ាង

---

[54] សូមមើលផងដែរ មាត្រា ២(ឈ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ សូមមើលអត្ថបទ "ចំនុចវិវាទដែលអាចសម្រេចសេចក្តីបានដោយវេទិការមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា" ដោយមេធាវីគីម សាន នៃព្រឹត្តិបត្រមេធាវី លេខ ១៤ ខែ កក្កដា-កញ្ញា ឆ្នាំ ២០១៧។

[55] មាត្រា ១ កថាខ័ណ្ឌ១ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានអនុម័ត នៅថ្ងៃទី ៦ ខែមីនា ឆ្នាំ ២០០៦ ។

[56] មាត្រា ១ កថាខ័ណ្ឌ២ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[57] មាត្រា១ កថាខ័ណ្ឌ១ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ធ្វើឡើង "......ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍នៃភាគីវិវាទទាំងនេះ...." ប៉ុណ្ណោះ។

ណាក៏ដោយ ការចែងដូច្នេះនៅតែចោទជាបញ្ហា នៃការបកស្រាយទូលំទូលាយលើពាក្យគោលនយោបាយសាធារណៈ ដែលនាំឲ្យមានការបដិសេធការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស។[58]

ដោយឡែក ស្តង់ដារក្នុងការកំណត់ថា ការអនុវត្តមួយធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈក្នុងប្រទេសកម្ពុជា ត្រូវពិចារណាលើស្តង់ដារនៃបន្ទាត់នយោបាយសាធារណៈដែលបានអនុវត្តដោយតុលាការនៃរដ្ឋដទៃទៀត នៃអនុសញ្ញាទីក្រុងញូយ៉ក(ក្នុងនាមជាភាគី)បានអនុវត្ត។[59] ផ្អែកតាមន័យនេះតុលាការប្រទេសកម្ពុជាអាចធ្វើការជ្រើសរើសបន្ទាត់នយោបាយសាធារណៈណាមួយឬច្រើនរបស់ប្រទេសដទៃដែលជាភាគីនៃអនុសញ្ញាដែលប្រហាក់ប្រហែល និងស្ថានភាពរបស់គោលនយោបាយរបស់ប្រទេសកម្ពុជា មុនឈានដល់ការសម្រេចមិនអនុវត្ត។ ប៉ុន្តែការជ្រើសរើសនេះ គួរសម្រួលដល់ការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ជាជាងបង្កឲ្យមានជាល័ក្ខខ័ណ្ឌតឹងរឹងជាង ដែលឈានដល់ការសម្រេចមិនអនុវត្តតាមអនុសញ្ញាទីក្រុងញូយ៉ក។[60] ដោយហេតុថា ជារឿយៗ ភាគីដែលនឹងទទួលការខូចខាតផលប្រយោជន៍ពីការអនុវត្តមជ្ឈត្តវិនិច្ឆ័យ លើកពីមូលហេតុទាំងអស់ខាងលើនៅក្នុងការស្នើបដិសេធរបស់ខ្លួន ការត្រួតពិនិត្យផ្អែកតុលាការ យ៉ាងទូលំទូលាយមិនងាយជៀសវាងបានឡើយ នៅពេលមានភាគីដែលលើកឡើងនោះ សំអាងបញ្ជាក់អំពីហេតុនោះ។[61]

## ៣. សេចក្តីសន្និដ្ឋាន

- តុលាការអនុវត្តអាចបដិសេធការទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសណាមួយតាមករណីលែកលែងប៉ុណ្ណោះ និងត្រូវធ្វើឡើងឲ្យស្របតាមមាត្រា៥.១ នៃអនុសញ្ញា ទីក្រុងញូយ៉កផងដែរ ដែលមាត្រានេះតម្រូវឲ្យភាគីដែលខូចខាត

---

[58] The Principles and Practice of International Commercial Arbitration, Margaret L. Moses, 2008, Page 218.

[59] មាត្រា ១៥.ខ.២ នៃច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេសចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០១។

[60] មាត្រា ៤ នៃច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេសចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០១ ចែងថា "តុលាការកម្ពុជាត្រូវតែសម្រេចឲ្យស្របតាមអនុសញ្ញាទីក្រុងញូយ៉ក ក្នុងការវិនិច្ឆ័យលើការទទួលស្គាល់ និងការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស។"

[61] International Commercial Arbitration for law students, Kindle Edition, Loc 4540 វាក៏ជាការអនុវត្តនៅក្នុងតុលាការ នៃយុត្តាធិការអនុវត្តភាគច្រើន ដែលរួមមានបញ្ហាទាំងអស់ដែលចែងនៅក្នុងការលើកលែង។

ប្រយោជន៍ផ្តល់ភស្តុតាងបង្ហាញថា មានឧបសគ្គក្នុងការទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យ។[62] មាត្រា ៣៥៣.៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនបានអនុញ្ញាតិឲ្យតុលាការអនុវត្តក្នុងស្រុក ធ្វើការស្រាវជ្រាវអំពីភាពត្រឹមត្រូវ ឬភាពមិនត្រឹមត្រូវ នៃខ្លឹមសារមជ្ឈត្តវិនិច្ឆ័យបរទេសឡើយ។

- ផ្អែកតាមក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជា តុលាការអនុវត្តមិនមានកាតព្វកិច្ច (តែមានសិទ្ធិ)[63] ក្នុងការជំទាស់មិនទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសឡើយ ហើយក៏មិនអាចជំទាស់មិនអនុវត្តតាមមជ្ឈត្តវិនិច្ឆ័យបរទេស ដោយការផ្តួចផ្តើមផ្ទាល់ខ្លួន ដោយអនុលោមតាមមាត្រា ៥. ១ នៃអនុសញ្ញាទីក្រុងញូយ៉ក។[64]

---

[62] Non-Recognition of Foreign Arbitral Awards Pursuant to Article V 1 d of the New York Convention, Juridiskā zinātne / Law, No. 6, 2014, ទំព័រ160។

[63] ដូចខាងលើ (លេខ៣០)។

[64] មាត្រា ៥.២ នៃអនុសញ្ញាទីក្រុងញូវយ៉ក តម្រូវឲ្យមានល័ក្ខខ័ណ្ឌ២ ដើម្បីតុលាការអនុវត្ត អាចចូលអន្តរាគមន៍បាន ១. មានការស្នើពីភាគីដែលនឹងខាតប្រយោជន៍ ២. ភាគីដែលខាតប្រយោជន៍ត្រូវផ្តល់ភស្តុតាងនៃឧបសគ្គទាក់ទងនឹងការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេសនោះ។

# ហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ

ដោយលោក ខន សុខេង*

## ១. សេចក្ដីផ្ដើម

ក្រោយពីសង្គ្រាមត្រជាក់បានបញ្ចប់មក ពិភពលោកបានផ្ដល់តម្លៃផ្នែកសេដ្ឋកិច្ចយ៉ាងខ្លាំង ដោយបានបញ្ចប់ការប្រជែងផ្នែកមនោគមវិជ្ជា ដោយហេតុថាមានតែភាពសម្បូររុងរឿងកំណើនសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទើបជាសុខសន្តិភាពពិតប្រាកដរបស់ពិភពលោក។ ប្រទេសនីមួយៗបានទាក់ទាញការធ្វើវិនិយោគិនពីបរទេស ដោយផ្សារភ្ជាប់នូវទំនាក់ទំនងពីតំបន់មួយទៅតំបន់មួយ និងពីទ្វីបមួយទៅទ្វីបមួយ ក្នុងនោះផងដែលមានការបង្កើត អង្គការ ស្ថាប័នដើម្បីបង្កើនទំនាក់ទំនងរវាងរដ្ឋ និង រដ្ឋ ដូចជា សហភាពអឺរ៉ុប សហភាពអាហ្វ្រិច និងសមាគមប្រទេស BRICS[65]។ លើសពីនេះទៅទៀតអង្គការតំបន់មួយដែលហៅថាអាស៊ានបានចាប់បដិសន្ធិឡើង ដោយសេចក្ដីប្រកាសនាទីក្រុងបាងកក នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ ១៩៦៧ ដោយមានប្រទេសជាស្ថាបនិកមានចំនួនប្រាំដូចជាប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ សឹង្ហបុរី និងជាសមាជិកមានប្រទេសព្រុយណេដារ៉ូសាឡឹម វៀតណាម ឡាវ មីយ៉ាន់ម៉ា (ឬភូមា) និងព្រះរាជាណាចក្រកម្ពុជា ។

ងាកមកមើលបរិបទកម្ពុជាវិញឃើញថា ប្រទេសមួយនេះបានឆ្លងកាត់នូវរបត់នយោបាយ និងរបត់សេដ្ឋកិច្ចជាច្រើនលើកច្រើនសារ និងបានបន្តវិវត្តន៍រហូតដល់បច្ចុប្បន្ន។ ការវិវត្តន៍ខាងផ្នែកនយោបាយបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រព័ន្ធសេដ្ឋកិច្ចកម្ពុជា។

ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧០ សម័យកាលព្រះរាជាណាចក្រកម្ពុជាទទួលបានឯករាជ្យ និងកសាងសង្គមរាស្ត្រនិយម ដោយបានអនុម័តយកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី បន្ទាប់មកជាតូបនីយកម្មវិស័យសេដ្ឋកិច្ច។ ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ សម័យសាធារណរដ្ឋខ្មែរបាន

---

* អ្នកនិពន្ធបច្ចុប្បន្នធ្វើការជាឧបការីព្រឹទ្ធបុរស និងសាស្ត្រាចារ្យច្បាប់ នៅសាកលវិទ្យាល័យកម្ពុជា។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតច្បាប់ ផ្នែកនីតិភូមិបាល និងបេតិកភ័ណ្ឌដែលសហប្រតិបត្តិការរវាង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច និងសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣។ លោកក៏ទទួលបាននូវសញ្ញាបត្រ High Diploma ផ្នែកនីតិភូមិបាល និងបេតិកភ័ណ្ឌពីសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣ ផងដែរ។ អ្នកនិពន្ធបានបញ្ចប់ថ្នាក់បរិញ្ញាបត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច និងបរិញ្ញាត្របត្រភាសាអង់គ្លេស TEFL ពី សាកលវិទ្យាល័យធនធានមនុស្ស។

[65] សមាគមប្រទេសBRICS មានប្រាំប្រទេស(ប្រទេស ប្រេស៊ីល រូស៊ី ឥណ្ឌា ចិន និង អាហ្វ្រិកខាងត្បូង)

អនុម័តយកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។ ហើយពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ សម័យកម្ពុជាប្រជា-ធិបតេយ្យ សេដ្ឋកិច្ចផែនការ ការប្រមូលផ្តុំដោយពឹងផ្អែកលើកសិកម្ម និងធ្វើសហករណ៍នីយកម្មបែបចិនកុំម្មុយនីស។ ដល់ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ សម័យសាធារណរដ្ឋកម្ពុជាអនុវត្តសេដ្ឋកិច្ចផែនការប្រមូលផ្តុំបែបសូវៀត។ ហើយនឹងពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៣ សម័យរដ្ឋកម្ពុជា សេដ្ឋកិច្ចផែនការប្រមូលផ្តុំបើកទូលាយសេដ្ឋកិច្ចទីផ្សារ។ ពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ននេះបានអនុវត្តសេដ្ឋកិច្ចអន្តរកាលទៅកាន់ទីផ្សារសេរី ហើយប្រទេសកម្ពុជាបានខិតខំធ្វើសមា-ហរណកម្មចូលជាសមាជិកអាស៊ាននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ និងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ២០០៤ ដែលជាចរន្តការមួយក្នុងការនាំលំហូរអ្នកវិនិយោគទុនមកប្រទេសយើងដែរ តាមរយៈកំណែទម្រង់ឲ្យមានដំណើរការល្អលើលទ្ធិប្រជា-ធិបតេយ្យ និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ដោយមានការអនុម័តបទបញ្ញត្តិថ្មី និងគោលនយោ-បាយថ្មី និងបន្តកំណែទម្រង់ប្រព័ន្ធតុលាការ[66]។

ការចូលទៅអង្គការតំបន់បាននាំនូវកាលានុវត្តភាពដល់ប្រទេសកម្ពុជាក្នុងការទាញយកផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចក្រោយពីប្រទេសយើងបានបញ្ចប់សង្គ្រាម និងមានការបោះឆ្នោតបែបប្រជាធិបតេយ្យ។ លើសពីនេះ ការថែរក្សាស្ថេរភាពនយោបាយក៏ជាចលករមួយយ៉ាងសំខាន់ផងដែរក្នុងការគៀងគរវិនិយោគិនបរទេសមកដាក់ទុននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នាពេលបច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី[67]។ នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយមួយចំនួនដូចជា ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដោយក្នុងនោះខិតខំសម្រេចឲ្យបានកំណើនសេដ្ឋកិច្ចជាមធ្យម ៧ (ប្រាំពីរ) ភាគរយដើម្បីធ្វើឲ្យកម្ពុជាអាចចាកចេញផុតពីប្រទេសមានចំណូលទាប[68] និងគាំទ្រគន្លឹះជាអាទិភាពសម្រាប់គាំទ្រការអភិវឌ្ឍន៍វិស័យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយក្នុងនោះកំណត់អត្តសញ្ញាណ និងដោះស្រាយហានិភ័យ ដោយចាត់ទុកអ្នកផ្តល់សេវាហិរញ្ញវត្ថុស្មើភាពគ្នាដើម្បីផ្តល់ជាទីលានប្រកួតប្រជែងស្មើភាពមួយ និងជៀសវាងការអនុវត្តបទបញ្ញត្តិតាមទំនើងចិត្ត[69]។

---

[66] ភូមិវិទ្យាសេដ្ឋកិច្ចនៅព្រះរាជាចក្រកម្ពុជា) និង DFDL Real Estate investment guide edition in 2013

[67] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[68] កម្មវីធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ខែកញ្ញា ឆ្នាំ២០១៣

[69] យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យវិនិយោគអចលនវត្ថុមានការកើនឡើងគួរឲ្យកត់សម្គាល់ដោយ ក្នុងនោះមានវិនិយោគិនដែលដាក់ទុនលើវិស័យអចលនទ្រព្យមានការកើនឡើងគួរកត់សម្គាល់ ទៅលើ ខុនដូ (Apartment) អាផាតមិន ផ្សារទំនើប មជ្ឈមណ្ឌលពាណិជ្ជកម្ម និងគម្រោងក្រុងរណបមួយ ដែលកំពុងតែនៅប្រតិបត្តិការ និងកំពុងសាងសង់។ ជាមួយនឹងការងើបឡើងវិញនៃទីផ្សារអចលនទ្រព្យនៅចុងឆ្នាំ២០១១ នេះគេសង្កេតឃើញសំណង់អគារខ្ពស់ៗ បែបអាផាតមិន ឬខុនដូ បានងើបឡើងវិញយ៉ាងត្រដែតត្រដឹមក្នុងទីក្រុងភ្នំពេញសម្រាប់លក់ ឬជួលឲ្យអតិថិជនរស់នៅ។ កាលពីមុន ប្រទេសកម្ពុជាមិនធ្លាប់មានសំណង់អគារខ្ពស់ៗបែបនេះនោះទេ ប៉ុន្តែជាទូទៅ ប្រជាពលរដ្ឋខ្មែរមិនទម្លាប់និយមរស់នៅក្នុងផ្ទះ ឬអគារខ្ពស់ៗបែបនេះឡើយ ដោយពួកគាត់ធ្លាប់រស់នៅក្នុងផ្ទះមួយដាច់តែឯង ហើយពួកគាត់គិតថា វាមិនមានសិទ្ធិសេរីភាពក្នុងការរស់នៅឡើយ តែសម្រាប់ជនជាតិបរទេស គេចូលចិត្ត ឬនិយមរស់នៅជាលក្ខណៈគ្រួសារ ក្នុងផ្ទះបែបអាផាតមិន ឬខុនដូខ្ពស់ៗនេះណាស់ ពីព្រោះវាមានសុវត្ថិភាព និងមានភាពងាយស្រួលក្នុងការរស់នៅ ហើយសំណង់អគារខ្ពស់ៗបែបអាផាតមិន ឬខុនដូនេះភាគច្រើនគេសាងសង់សម្រាប់តម្រូវការជនបរទេស។ ការងើបឡើងវិញនៃទីផ្សារអចលនទ្រព្យនេះ ត្រូវបានអ្នកជំនាញមើលឃើញថា វាងើបតែតម្រូវការអចលនទ្រព្យ ប៉ុណ្ណោះតែហាងឆេងតម្លៃរបស់វា គឺនៅដដែលមិនទាន់ងើបនៅឡើយទេ នោះរាប់ទាំងដីធ្លីផងដែរ ។

ការងើបឡើងនេះ ដោយសារតែលំហូរចូលនៃការវិនិយោគពីប្រទេសជប៉ុន ចិន ម៉ាឡេស៊ី សិង្ហបុរី និងវៀតណាម ដែលកំពុងតែប្រកួតប្រជែងគ្នាមែនទែនក្នុងការចូលមកវិនិយោគនៅក្នុងប្រទេសកម្ពុជា។ ការងើបឡើងវិញនៃទីផ្សារអចលនទ្រព្យនាពេលនេះ វាមិនមែនជាការងើបឡើងនៃតម្លៃអចលនទ្រព្យនោះទេ នៅក្នុងដំណាក់កាលដំបូងនេះ វាគ្រាន់តែកើនឡើងនៃតម្រូវការអចលនទ្រព្យប៉ុណ្ណោះ។ នៅឆ្នាំនេះ ឬឆ្នាំក្រោយ គេមើលឃើញថា វាមិនទាន់ដល់ពេលដែលអចលនទ្រព្យត្រូវឡើងថ្លៃនោះទេ ការកើនឡើងនៃតម្រូវការនាពេលនេះ វាបំពេញឱ្យចន្លោះប្រហោងកាលពីឆ្នាំមុន ប្រសិនបើវាបន្តងើបឡើងរយៈពេលពីរឆ្នាំជាប់គ្នាតទៅមុខទៀត តម្លៃអចនទ្រព្យនឹងកើនឡើងជាងសព្វថ្ងៃនេះ ហើយការងើបឡើងនេះក៏ពឹង ផ្អែកទៅលើផលិតផលសរុបក្នុងស្រុក របស់យើងផងដែរ ។

នៅពេលសំណង់អគារបែបអាផាតមិន ឬខុនដូបានងើបឡើងព្រោងព្រាត នៅក្នុងទីក្រុងកាន់តែច្រើនឡើងៗ នោះត្រូវបានម្ចាស់អាផាតមិន ឬ ខុនដូមួយចំនួនលើកឡើងថា កាលណាមានការផ្គត់ផ្គង់ច្រើនពេក វាប្រាកដជាធ្វើឲ្យតម្រូវការធ្លាក់ចុះ ដោយសារភាគច្រើនជាភ្ញៀវ

បរទេស គឺមានចំនួនប្រហែល៨០ភាគរយ តែភ្ញៀវក្នុងស្រុកមានតែ២០ភាគរយប៉ុណ្ណោះ ដែលមានលទ្ធភាពមកជួលខុនដូស្នាក់នៅ ប៉ុន្តែឥឡូវនេះវាបានធ្លាក់ចុះភ្ញៀវ ហើយការធ្លាក់ចុះនេះ។[70] ការធ្លាក់ចុះក្នុងរយៈពេលនេះ គឺដោយសារភ្ញៀវមួយចំនួនធ្វើដំណើរទេសចរណ៍ច្រើន ហើយភ្ញៀវមួយចំនួន គេចប់អាណត្តិរបស់គេដែលវាធ្វើឱ្យចំនួនភ្ញៀវស្នាក់នៅមានការថយចុះ។ បើអគារ អាផាតមិន ឬខុនដូរីកដុះដាលកាន់តែច្រើន វាធ្វើឲ្យការប្រកួតប្រជែងក៏កាន់តែខ្លាំងដែរ ប៉ុន្តែវាអាស្រ័យទៅតាមកម្រិតស្តង់ដារនៃ អគារនីមួយៗដែលម្ចាស់អគារខ្លះគេយកចិត្តទុកដាក់ទៅលើការបំពាក់សម្ភារៈទំនើបៗ និងការរៀបចំផ្នែកខាងក្នុង ហើយតម្លៃនៃការជួលក៏គេគិតទៅតាមសម្ភារៈដែលគេបំពាក់នៅខាងក្នុងនោះដែរ ។

ទាក់ទងនឹងគម្រោងសាងសង់ ដែលដែលរាជរដ្ឋាភិបាលបានអនុម័ត នាពេលកន្លងមកដែលតួលេខបានមកពី នាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានឲ្យដឹងថា ចាប់ពីដើមឆ្នាំ រហូតដល់ ខែកក្កដា ក្នុងឆ្នាំ២០១១នេះ គម្រោងសាងសង់ ដែលរាជរដ្ឋាភិបាលបានអនុម័តមានចំនួនទឹកប្រាក់៧៤៧,៧លានដុល្លារ បើគិតជាគម្រោងមានចំនួន១.២៧៩ គម្រោង ។ ក្នុងរយៈពេល ដូចគ្នាកាលពីឆ្នាំ២០១០មានចំនួន១.៣៤៤ គម្រោងស្មើនឹងទឹកប្រាក់ចំនួន៤០៥,៨លានដុល្លារ តែបើគិតជាគម្រោងក្នុងរយៈពេលដូចគ្នា ក្នុងឆ្នាំនេះមានការថយចុះតែទឹកប្រាក់វិនិយោគមានចំនួនច្រើនជាងឆ្នាំមុន។[71]

ដោយមើលឃើញពីភាពអំណោយផលលើបរិយាកាសអាជីវកម្មលើវិស័យអចលនវត្ថុនេះ បានជាវិនិយោគិនមួយចំនួនបានចាប់អារម្មណ៍លើការធ្វើហិរញ្ញប្បទានដើម្បីទទួលបានធនធាននេះយកទៅអភិវឌ្ឍន៍គម្រោងអភិវឌ្ឍន៍អចលនវត្ថុ។ មានប្រភេទហិរញ្ញប្បទានជាច្រើនដែលអនុញ្ញាតឲ្យម្ចាស់គម្រោងអចលនវត្ថុទទួលបានហិរញ្ញប្បទានដូចជា ហិរញ្ញប្បទាន តាមរយៈធនាគារហិរញ្ញប្បទានទីផ្សារមូលបត្រ និងហិរញ្ញប្បទានដោយមូលនិធិសមធម៌។ ក្នុងចំណោមប្រភេទហិរញ្ញប្បទាននិងប្រភេទដែលពេញនិយម និងទូលំទូលាយជាងគេគឺហិរញ្ញប្បទានដោយធនាគារ។

តើមានលក្ខខណ្ឌ និងយន្តការណាខ្លះដើម្បីអនុញ្ញាតឲ្យម្ចាស់គម្រោងអចលនវត្ថុទទួលបានហិរញ្ញប្បទានពីធនាគារ?

---

70 https://www.postkhmer.com/ប៉ុស្ដិ៍-អចលនទ្រព្យ/ចំនួនខុនដូបានកើនឡើងប្រហែល-២០-ភាគរយ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤

71 http://icamnews.wordpress.com/

ឆ្លើយតបនឹងបញ្ហាដែលបានចោទឡើងខាងលើ មានប្រធានបទមួយត្រូវបានលើកឡើងគឺ "ហិរញ្ញប្បទានដោយធនាគារលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ"។

មុននឹងស្វែងយល់លើប្រធានបទទាំងមូល ការសិក្សាពាក្យគន្លឹះមួយចំនួនគឺមានភាពចាំបាច់ ដូចជា ហិរញ្ញប្បទាន គម្រោងអភិវឌ្ឍន៍អចលនវត្ថុ ធនាគារ។

*ហិរញ្ញប្បទានៈ* គឺជាចលករដ៏ចម្បងដែលធានានូវការពង្រីកអាជីវកម្មរបស់ក្រុមហ៊ុន ឬសហគ្រាស ពីព្រោះការពង្រីកអាជីវកម្មត្រូវការបង្កើនការផលិតហើយការបង្កើនការផលិតគឺត្រូវការនូវមូលធន[72]។

*គម្រោងអភិវឌ្ឍន៍អចលនវត្ថុៈ* សំដៅដល់គម្រោងសាងសង់ ឬកែច្នៃអចលនវត្ថុក្នុងគោលបំណងដើម្បីលក់ ឬជួល។

*ធនាគារៈ* ធនាគារគឺជានីតិបុគ្គលដែលមាននីតិសម្បទាពិសេសក្នុងការជ្រើសរើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតី[73]។ ប្រតិបត្តិការដែលជាសកម្មភាពរួមមានៈ

១.ការផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណជន ដោយមានកម្រៃ រាប់បញ្ចូលទាំង ឥណទានភតិសន្យា និង ការសន្យាតាមហត្ថលេខា។

២. ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាពីសាធារណជន

៣. ប្រព្រឹត្តកម្ម និងការដាក់ឲ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុ ឬជារូបិយប័ណ្ណ[74]។

ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងយល់ប្រធានបទនេះ ឲ្យបានប្រសើរអត្ថបទនេះនឹងធ្វើការបង្ហាញដោយធ្វើការបែងចែកប្លង់ជាពីរជំពូកគឺៈ ជំពូកទី ១ និងធ្វើការលើកឡើងអំពីការទទួលបានហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ។ ចំណែកឯជំពូកទី២ និងរៀបរាប់អំពីការអនុវត្តកិច្ចសន្យាហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ។

## ជំពូកទី ១៖ ការទទួលបានហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ

នៅក្នុងជំពូកនេះយើងនឹងលើកឡើងអំពីលក្ខខណ្ឌនានាចាំបាច់ដើម្បីទទួលបានហិរញ្ញប្បទាន(**ផ្នែកទី១**) ព្រមទាំងលើកឡើងផងដែរអំពីការបង្កើតកិច្ចសន្យាក្នុងន័យបង្កើតសិទ្ធិ និង

[72] ហិរញ្ញប្បទានរបស់ក្រុមហ៊ុនពាណិជ្ជកម្មតាមរយៈទីផ្សារមូលបត្រ(បោះពុម្ពលើកទី១ ឆ្នាំ២០០៩)

[73] មាត្រា ១នៃ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ. នស/រកម/១១៩៩/១៣. ១៨ វិច្ឆិកា ១៩៩៩

[74] មាត្រា ២នៃ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ. នស/រកម/១១៩៩/១៣. ១៨ វិច្ឆិកា ១៩៩៩

ចងជាកាតព្វកិច្ចចំពោះភាគីទាំងសងខាងរវាងធនាគារ និងម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ **(ផ្នែកទី២)**។

*ល័ក្ខខ័ណ្ឌទទួលបានហិរញ្ញប្បទាន*

ក្នុងក្របខណ្ឌនៃការផ្តល់ហិរញ្ញប្បទានជូនអតិថិជន ការសិក្សាវាយតម្លៃលម្អិតលើប្រវត្តិ និងលទ្ធភាពសងត្រលប់មកវិញនូវកាតព្វកិច្ចគឺជាកិច្ចការចាំបាច់បំផុតរបស់ធនាគារ។ លើសពីនេះទៅទៀត ការសិក្សាលើអត្ថិភាពលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុក៏ជាកិច្ចការមួយសំខាន់ផងដែរ ដើម្បីចៀសវាងនូវហានិភ័យ ក៏ដូចជាការទាក់ទាញគម្រោងអភិវឌ្ឍន៍ផ្សេងទៀតមានការចាប់អារម្មណ៍ ហើយងាកមកទទួលយកសេវាកម្មរបស់ធនាគារ។ ដើម្បីបង្ហាញឲ្យកាន់តែមានភាពច្បាស់លាស់លើ ទិដ្ឋភាពខាងលើ អត្ថបទនេះនឹងធ្វើការបង្ហាញជាបឋមអំពីបុរេវិនិច្ឆ័យក្នុងការផ្តល់ហិរញ្ញប្បទាន (កថាខណ្ឌទី១) ហើយបន្ទាប់មកទៀតនឹងធ្វើការលើកឡើងអំពីការសិក្សារបស់ធនាគារលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុរបស់អតិថិជនដែលជាអភិវឌ្ឍន៍អចលនវត្ថុ(កថាខណ្ឌទី២)។

*កថាខណ្ឌទី១៖ បុរេវិនិច្ឆ័យក្នុងការទទួលហិរញ្ញប្បទាន*

លក្ខខណ្ឌបុរេវិនិច្ឆ័យពិតជាមានសារៈសំខាន់ណាស់ មុននឹងធនាគារផ្តល់នូវហិរញ្ញប្បទានទៅដល់បណ្តាក្រុមហ៊ុន សហគ្រាស ក៏ដូចជាបណ្តាអតិថិជនផ្សេងទៀត ជាពិសេសម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុដែលមានគោលបំណងចង់ទទួលយកសេវាហិរញ្ញប្បទានធនាគារ។ តើធនាគារ និងសិក្សាវាយតម្លៃអ្វីខ្លះមុននឹងផ្តល់ហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ?

នៅក្នុងកថាខណ្ឌនេះនឹងលើកឡើងអំពីការសិក្សាសំខាន់ៗដើម្បីឆ្លើយតបទៅនឹងការលើកឡើងដោយ ពិនិត្យមើលជាបឋមអំពីការសិក្សាអំពីអត្តសញ្ញាណរបស់ម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ។ ជាបន្ទាប់នឹងធ្វើការលើកឡើងអំពី ក្រុមប្រឹក្សាភិបាលនៃគម្រោង (Board of Directors)។ ជាចុងក្រោយនឹងធ្វើការបង្ហាញពីប្រវត្តិនៃការចរាចរណ៍ផ្នែកហិរញ្ញវត្ថុរបស់ក្រុមដែលធ្វើអាជីវកម្ម។

***១. ការសិក្សាអត្តសញ្ញាណក្រុមហ៊ុន***

នៅក្នុងការសិក្សាទីនេះនឹងបង្ហាញឲ្យឃើញថាតើក្រុមហ៊ុននោះមានអត្ថិភាពពិតប្រាកដដែរឬទេ? តើមានការចុះបញ្ជីការនៅក្នុងអង្គភាពពាក់ព័ន្ធដែរឬទេ?តើមានការចុះបញ្ជីលក្ខន្តិកៈដែរឬទេ? តើមានអាជ្ញាប័ណ្ណក្នុងការប្រកបអាជីវកម្មដែរឬទេ? តើមានប័ណ្ណប៉ាតង់ដែលមានសុពលភាពក្នុងការប្រកបអាជីវកម្មឬទេ? ដូច្នេះជាបឋម ធនាគារពិនិត្យមើលអំពីវិញ្ញាបនប័ត្រ

បញ្ជាក់ពីការចុះឈ្មោះក្នុងបញ្ជីពាណិជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្មដែលកំពុងមានសុពលភាពប្រើប្រាស់។ បន្ថែមពីនេះធនាគារ នឹងពិនិត្យមើលផងដែរអំពីការចុះបញ្ជីលក្ខន្តិកៈរបស់ក្រុមហ៊ុន។

នៅក្នុងទិដ្ឋភាពមួយផ្សេងទៀតធនាគារនឹងពិនិត្យមើលសុពលភាពនៃអាជ្ញាប័ណ្ណប្រកបអាជីវកម្មដែលចេញដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ពិនិត្យមើលផងដែរប័ណ្ណអាជីវកម្មប្រចាំឆ្នាំដែលកំពុងមានសុពលភាពប្រើប្រាស់ដែលដោយ សាខាពន្ធដារដែលសកម្មភាពអាជីវកម្មនោះស្ថិតនៅ។

### ២. ការសិក្សាអំពីក្រុមប្រឹក្សាភិបាលនៃគម្រោង (Board of Directors)

ហេតុអ្វីបានជាមានភាពចាំបាច់សិក្សាអំពីក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន? រាល់ការសម្រេចដែលជាភាពចាំរបស់ក្រុមហ៊ុនត្រូវបានអនុវត្តយល់ព្រមពីក្រុមប្រឹក្សាភិបាល លើសពីនេះទៀតពួកគាត់ជាអ្នកដោះស្រាយរាល់បញ្ហាប្រឈមរបស់ក្រុមហ៊ុន ក្នុងនោះលើផ្នែកហិរញ្ញវត្ថុនិងដំណើរការប្រក្រតីភាពរបស់ក្រុមហ៊ុន។ សម្រាប់ក្រុមហ៊ុនខ្លះមានការបែងចែករវាងអំណាចរបស់ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុន។ ជាទូទៅកិច្ចការសំខាន់របស់ក្រុមហ៊ុន ដែលជាអាយុជីវិតរបស់ក្រុមហ៊ុន ត្រូវសម្រេចដោយម្ចាស់ភាគហ៊ុន ឧទាហរណ៍ លក់អចលនទ្រព្យរបស់ក្រុមហ៊ុន ការភ្ជាប់កាតព្វកិច្ចបំណុល ខ្ចីបុល ។ល។ ដែលត្រូវសម្រេចដោយម្ចាស់ភាគហ៊ុនតាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

ការសិក្សាអំពីអត្តសញ្ញាណផ្ទាល់របស់ក្រុមប្រឹក្សាភិបាល គឺជាភាពចាំបាច់មួយសម្រាប់ហិរញ្ញប្បទានិក មុននឹងសម្រេចចិត្តក្នុងការផ្តល់នូវហិញ្ញប្បទានលើគម្រោងអភវឌ្ឍន៍អចលនវត្ថុក្នុងនោះការសិក្សាត្រូវបានកំណត់ដូចខាងក្រោមៈ

**២.១. ការពិនិត្យមើលទៅលើអត្តសញ្ញាណកម្មៈ** តើមានភាពចាំបាច់អ្វីត្រូវធ្វើការពិនិត្យលើអត្តសញ្ញាណកម្មរបស់ក្រុមប្រឹក្សាភិបាល? ក្នុងនោះវាទាក់ទងទៅនឹងសេចក្តីសម្រេចចិត្តរបស់ក្រុមហ៊ុន និងតើក្រុមហ៊ុនវាត្រូវបានកាន់កាប់ ដោយម្ចាស់ភាគហ៊ុនជាបរទេសឬក៏ម្ចាស់ហ៊ុនជាខ្មែរ ហើយការការសិក្សានេះក៏បង្ហាញនូវទំនុកចិត្តរបស់ធនាគារដល់ក្រុមហ៊ុន។ ការលើកឡើងនេះគឺស្ថិតនៅក្នុងលក្ខខណ្ឌដែលក្រុមប្រឹក្សាភិបាលជា ម្ចាស់ភាគហ៊ុន។

**២.២. ការត្រួតពិនិត្យអំពីលិខិតថ្កោលទោស និង ទណ្ឌកម្មផ្សេងៗទៀតៈ** ការត្រួតពិនិត្យលើលិខិតថ្កោលទោស គឺជាវត្ថុបំណងមួយត្រួតពិនិត្យលើសាវតារបស់ក្រុមប្រឹក្សា-ភិបាលថាតើធ្លាប់មានប្រវត្តិជាប់ទោស ពីបទឧក្រិដ្ឋកម្មក្នុងរឿងព្រហ្មទណ្ឌ ការពិន័យខាងផ្នែក

ស៊ីវិល និងការក្បៀយធនបុគ្គលជាដើម។ រាល់បទដែលបានរៀបរាប់ខាងលើ វាបានបង្កជាផលប៉ះពាល់ដល់ហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ។

**២.៣. ប្រវត្តិការងារ និងចរិតលក្ខណៈក្នុងសង្គម៖** ធនាគារគេនឹងសិក្សាទៅលើប្រវត្តិនៃការដឹកនាំក្រុមហ៊ុនអាជីវកម្មរបស់ក្រុមប្រឹក្សាភិបាលថាតើ មានប្រវត្តិនៃការសងធនាគារមានការយឺតយ៉ាវដែរឬទេ? មានកម្រិតទំនួលខុសត្រូវ និងគុណតម្លៃយ៉ាងដូចម្ដេច? ក្នុងនោះផងដែរកម្រិតនៃការអប់រំ និងបទពិសោធន៍ការងារក្នុងអាជីវកម្មជាដើម។ ហេតុដូចនេះហើយបានជាធនាគារទាមទារឲ្យមានការភ្ជាប់មកជាមួយលក្ខន្តិកៈនៃ ក្រុមហ៊ុនដើម្បីឲ្យធនាគារពិនិត្យមើលនូវលទ្ធភាពក្នុងការគ្រប់គ្រង ដឹកនាំក្រុមហ៊ុន។

### *៣.ការសិក្សាលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន*

ធនាគារត្រូវវិភាគផងដែរលើស្ថានភាគហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ការសិក្សានេះអនុញ្ញាតឲ្យធនាគារបានមើលឃើញអំពីលទ្ធភាពនៃការសងត្រលប់មកវិញរបស់ក្រុមហ៊ុន។ តើនៅក្នុងផ្នែកនេះធនាគារត្រូវត្រួតពិនិត្យ និងសិក្សាលើចរន្តការហិរញ្ញវត្ថុយ៉ាងដូចម្ដេចខ្លះ?

**៣.១.ប្រវត្តិហិរញ្ញវត្ថុរបស់ក្រុមហ៊ុន៖** ធនាគារនឹងត្រូវត្រួតពិនិត្យលើរបាយ-ការណ៍ហិរញ្ញវត្ថុ២ ឬ៣ឆ្នាំ មុននឹងសំណើរសុំហិរញ្ញប្បទានក្នុងកាងអភិវឌ្ឍន៍គម្រោង ដោយត្រួតពិនិត្យលើរបាយការណ៍ តារាងសមតុល្យ របាយការណ៍ចំណេញ ឬខាត របាយការណ៍លំហូរសាច់ប្រាក់ និង របាយការណ៍ទ្រព្យសម្បត្តិ។

**៣.២. របាយការណ៍សវនកម្ម៖** ភាពចាំបាច់មួយទៀតហិរញ្ញប្បទានិកក៏តម្រូវឲ្យមានរបាយការណ៍សវនកម្មដើម្បីត្រួតពិនិត្យលើភាពប្រក្រតី ឬភាពមិនប្រក្រតីនៃនៃការប្រើប្រាស់មូលធននៅក្នុងក្រុមហ៊ុន។ សវនកម្មជា ការពិនិត្យឯករាជ្យនៃគណនីរបស់ក្រុមហ៊ុន និងការកត់ត្រារបាយការណ៍ហិរញ្ញវត្ថុ វិភាគ លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

**៣.៣. ការប្រមើលមើលអំពីហិរញ្ញវត្ថុអនាគត៖** គឺជាការរំពឹងទុករបស់គ្រឹះស្ថានធនាគារនូវប្រាក់ចំណូល ប្រាក់ចំណាយ និងប្រាក់ចំណេញ ប្រចាំខែរបស់ក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុដោយ ធ្វើការសិក្សានូវទំហំតណទានដែលក្រុមហ៊ុនបានប្រើប្រាស់ទៅលើតម្លៃនៃសាងសង់គម្រោង តម្លៃនៃការថែទាំគ្រប់គ្រង ការចំណាយទៅលើបុគ្គលិកជាដើម។ របៀបនៃការបង្កើតនូវទស្សន៍ទាយអំពីហិរញ្ញវត្ថុរបស់ក្រុមហ៊ុនគឺ មានយន្តការដូចគ្នាទៅនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនតែមានចំណុចខុសគ្នាត្រង់ថា របាយការណ៍ហិរញ្ញវត្ថុបង្កើតឡើងនូវអ្វីដែលបានកើតឡើងរួចហើយ ចំណែកឯការទស្សន៍ទាយអំពីហិរញ្ញវត្ថុអនាគតគឺទស្សន៍ទាយ

នូវអ្វីៗដែលកើតឡើងនាពេលអនាគត។ គោលគំនិតសំខាន់នៃការទស្សន៍ទាយអំពីហិរញ្ញវត្ថុអនាគត គឺផ្តោតសំខាន់លើធាតុផ្សំបី៖ ការសិក្សាលើចំណូល(Revenue) ការសិក្សាអំពីការចំណាយ (Cost of Goods sold) និងការសិក្សាអំពីផលចំណេញ។ វាជាទស្សនទានបីសំខាន់ដែលសហគ្រិនតែងយកមកប្រើប្រាស់ក្នុងអាជីវកម្ម។

*ការសិក្សាលើគម្រោង*

ក្រៅពីសិក្សាអំពីបុរេវិនិច្ឆ័យ ធនាគារក៏សិក្សាផងដែរ លើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ តើធនាគារត្រូវសិក្សាលើចំណុចសំខាន់ៗអ្វីខ្លះដែលជាសក្តានុពលរបស់ម្ចាស់គម្រោង? មុននឹងផ្តោតយកចិត្តទុកដាក់ទៅលើចំណុចនានានៃ គម្រោងអភិវឌ្ឍន៍អចលនវត្ថុយើងត្រូវស្វែងយល់អំពីសញ្ញាណនៃគម្រោងអភិវឌ្ឍន៍អចលនវត្ថុ។

ការរៀបចំគម្រោងអភិវឌ្ឍន៍អចលនវត្ថុដើម្បីឲ្យធនាគារពិនិត្យលើសក្តានុពលដើម្បីផ្តល់ភាពទាក់ទាញហិរញ្ញប្បទានិកក្នុងការផ្តល់នូវហិរញ្ញប្បទាន នោះគេត្រូវសិក្សាលើចំណុចដូចខាងក្រោម៖

ការសិក្សាអំពីគម្រោងអភិវឌ្ឍន៍អចលនវត្ថុ មានន័យថា តើគម្រោងអភិវឌ្ឍន៍គឺធ្វើឡើងបែបណាលើដីដែលមានកម្មសិទ្ធិ ឬជួលរយៈពេលវែង។ តើគម្រោងចំណាយពេលវេលាប៉ុន្មានដើម្បីទទួលបានការកក់ពីអតិថិជន តើគម្រោងធ្វើឡើងមានរចនាបថនិងរៀបចំទីផ្សារទាក់ទាញនិងស្របតាមតម្រូវការរបស់អតិថិជនដែរឬទេ? តើគម្រោងនេះសមស្របនឹងទីផ្សារ ដែលអាចឲ្យក្រុមហ៊ុនទទួលបានការលក់ និងគម្រោងអាចប្រមូលទុនមកទូទាត់សំណងដល់ធនាគារ តើគម្រោងមានអ្វី ជាការដាក់ធានាសងកាតព្វកិច្ច។ល។

ពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ វាមានទិដ្ឋភាពពីរដែលបានមើលឃើញនាពេលបច្ចុប្បន្ននេះ នោះគឺការអភិវឌ្ឍន៍អចលនវត្ថុលើដីដែលជាកម្មសិទ្ធិ និងតាមរយៈយន្តការនៃការជួលរយៈពេលវែង។ តើប្រភេទនៃការអភិវឌ្ឍន៍មួយណាដែលពេញនិយមប្រើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ? ហេតុយ៉ាងដូចម្តេចបានជាគេប្រើយន្តការបែបនេះ?

*ការបង្កើតកិច្ចសន្យា*

នៅពេលដែលលក្ខខណ្ឌបុរេវិនិច្ឆ័យត្រូវបានធ្វើឡើងចប់សព្វគ្រប់ និងវិនិច្ឆ័យបានថាម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុមានលក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីទទួលបានហិរញ្ញប្បទាន នោះគេនឹងងាកមករកការបង្កើតកិច្ចសន្យាវិញម្តង ដោយចែងពីសិទ្ធិ និងកាតព្វកិច្ចចម្បងៗនៃកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ (**កថាខណ្ឌទី១**)។ លើសពីនេះដើម្បីបង្ការហានិភ័យក្នុងការ

អនុវត្តកាតព្វកិច្ចចម្បង នឹងនាំឲ្យមានការបង្កើតនូវកិច្ចសន្យាណាបមួយទៀតដែលត្រូវបានស្គាល់ថាជាសិទ្ធិប្រាតិភោគ(**កថាខណ្ឌទី២**)។

## កថាខណ្ឌ ទី១៖ កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

មុននឹងឈានដល់ការបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយ ភ្ជាប់ការប្រាក់ធនាគារត្រូវសិក្សាពីលក្ខខណ្ឌបុរេនិច្ច័យ និងពិនិត្យមើលអំពីលទ្ធភាពសងរបស់ក្រុមហ៊ុន (Credit Ratio) បើពិនិត្យឃើញថា មានលទ្ធភាពសងបំណុលបានធនាគារនឹងចេញលិខិតយល់ព្រមផ្តល់ប្រាក់កម្ចី (Letter of Offer or Letter of Credit) និងបើអ្នកកម្ចីឯកភាពថាយល់ព្រមខ្ចី នោះធនាគារតម្រូវឲ្យដាក់នូវឯកសារបន្ថែមពាក់ព័ន្ធ ដូចជា របាយការណ៍ហិរញ្ញវត្ថុ និងប័ណ្ណសម្គាល់ផ្សេងៗជាដើម រួចទើបមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀង។

តើកិច្ចសន្យាខ្ចីបរិភោគដែលភ្ជាប់ដោយមានការប្រាក់ត្រូវបាបង្កើតឡើងដោយលក្ខខណ្ឌគ្រឹះអ្វីខ្លះ? ហើយនៅក្នុងទិដ្ឋភាពជាក់ស្តែងតើកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់នេះមានចែងអំពីសិទ្ធិកាតព្វកិច្ចអ្វីខ្លះ?

### ១.ការបង្កើតកិច្ចសន្យាខ្ចីបរិភោគផ្អែកតាមក្រមរដ្ឋប្បវេណី

កិច្ចសន្យាខ្ចីបរិភោគ បង្កើតឡើងដោយការព្រមព្រៀងរបស់ភាគីទាំងសងខាង[75]។ ភាគីក៏អាចបង្កើតកិច្ចសន្យាដែលកម្មវត្ថុជាការសងប្រាក់តាមការព្រមព្រៀង។ ក៏ប៉ុន្តែការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ពុំមានអនុភាពឡើយ ប្រសិនបើពុំបានធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់អ្នកខ្ចី[76]។

ភាគីអាចបង្កើតកិច្ចសន្យាខ្ចីបរិភោគ ដោយមិនកំណត់អំឡុងពេលក្នុងការសងបាន។ ក៏ប៉ុន្តែវាមានភាពចាំបាច់ក្នុងការកំណត់ពីគុណភាព ចំនួន និងប្រភេទនៃកម្មវត្ថុ ដើម្បីបង្កើតកិច្ចសន្យាខ្ចីបរិភោគ។

### ២. ក្នុងទិដ្ឋភាពនៃការអនុវត្តជាក់ស្តែង

តើការចែងអំពីសិទ្ធិ និងកាតព្វកិច្ច ឬលក្ខខណ្ឌនានានៃកិច្ចសន្យាត្រូវបានកំណត់ដូចគ្នាចំពោះគ្រប់ធនាគារ ឬ យ៉ាងណា?

[75] មាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី

[76] មាត្រា ៥៨៣ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី

សិទ្ធិ និងកាតព្វកិច្ច ឬ ខសន្យាផ្សេងៗដែលបង្កើតឡើងដោយធនាគារមិនមានការចែងដូចគ្នាទាំងស្រុងចំពោះគ្រប់ធនាគារនោះទេ ដោយហេតុថាធនាគារនីមួយៗគេមានផែនការយុទ្ធសាស្ត្រផ្សេងៗ គ្នាក្នុងការផ្តល់នូវកាលានុវត្តភាពមួយដែលជាលក្ខខណ្ឌល្អប្រសើរសមស្របសម្រាប់ការទាក់ទាញអតិថិជនដែលមានសក្តានុពល។ មានន័យថា ការចងនូវទំហំសិទ្ធិ និងកាតព្វកិច្ចវាអាស្រ័យលើទំហំនៃហិរញ្ញប្បទាន ទំហំនៃសកម្មភាពអាជីវកម្មនៃគម្រោងអភិវឌ្ឍន៍អចលនវត្ថុ និងនិន្នាការនៃគោលនយោបាយរបស់ធនាគារនីមួយៗ។ តែគេអាចពិនិត្យមើលពីលក្ខខណ្ឌអប្បរមាដែលមានកំណត់ដូចខាងក្រោម៖

**២.១. ទំហំនៃឥណទាន៖** ទំហំឥណទានមិនមែនត្រូវបានផ្តល់ឲ្យតាមការស្នើសុំនោះឡើយ គឺអាស្រ័យលើទំហំនៃប្រាតិភោគដែលត្រូវបានធានាដោយអ្នកខ្ចីផងដែរ។ នៅក្នុងការផ្តល់ហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ
ទំហំនៃឥណទានត្រូវបានវាស់ស្ទង់ជាមួយ នឹងលទ្ធភាពនៃការសងបំណុល (Credit Ratio) ។

**២.២. ការកំណត់ពីអត្រាការប្រាក់៖** ក្នុងយន្តការហិរញ្ញប្បទានសម្រាប់កម្ចីដោយ ការព្រមព្រៀងនៃកិច្ចសន្យាខ្ចីបរិភោគ គេឃើញបែបបទនៃការចរចាចំពោះអត្រាការប្រាក់តាមសេចក្តីបញ្ជាក់នៃលិខិតស្នើសុំឥណទាន ដូចជា អត្រាការប្រាក់ធម្មតា និងអត្រាការប្រាក់ក្នុងការបំពានកិច្ចសន្យា ឬលក្ខខណ្ឌផ្សេងៗ ដូចកំណត់តាមការព្រមព្រៀងទាំងឡាយ។

ភាគីនៃកិច្ចសន្យាខ្ចីបរិភោគ អាចយកម្មវត្ថុនៃការសងការប្រាក់មកបង្កើតជាសិទ្ធិលើបំណុលតាមការព្រមព្រៀង[77]។ ទាក់ទងនឹងអត្រាការប្រាក់អាចកំណត់តាមច្បាប់ ឬដោយតាមការព្រមព្រៀងរបស់ភាគី[78]។

**២.២.១. អត្រាការប្រាក់តាមការព្រមព្រៀង៖** ក្នុងករណីមានការព្រមព្រៀង ពិសេសអំពីអត្រាការប្រាក់ ត្រូវអនុលោមការព្រមព្រៀង។ ភាគីអាចព្រមព្រៀងគ្នាដូចតទៅ៖

យកតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ គឺ ៥ % ក្នុងមួយឆ្នាំ[79]។

យកទាបជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់ ឧទាហរណ៍ ៣%ក្នុងមួយឆ្នាំ។

យកលើសពីអត្រាការប្រាក់ដែលច្បាប់បានកំណត់ ឧទាហរណ៍ ១០% ក្នុងមួយឆ្នាំ។

ក្នុងករណីភាគីកំណត់យកអត្រាការលើសពីអត្រាការប្រាក់ដែលច្បាប់បានកំណត់ ការកំណត់នោះ មិនត្រូវឲ្យលើសពីអត្រាការប្រាក់ដែលច្បាប់បានកម្រិតឡើយ[80]។

---

[77] មាត្រា ៥៨៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី

[78] មាត្រា ៥៨៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

[79] មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី

អត្រាការប្រាក់ដែលច្បាប់បានកម្រិតគឺមិនឲ្យលើសពី ១៨%ក្នុងមួយឆ្នាំ[81]។

ចំពោះវិស័យធានាគារគឺ អត្រាការប្រាក់មានលក្ខណៈជាសេរីភាពក្នុងការកំណត់ដោយធនាគារ និងការប្រកួតប្រជែងក្នុងចំណោមធានាគារ។

**២.២.២. អត្រាការប្រាក់តាមច្បាប់៖** ក្នុងករណីគ្មានការព្រមព្រៀងពិសេសណាមួយទេអំពីអត្រាការប្រាក់ត្រូវអនុលោមតាមអត្រាការប្រាក់ដែលច្បាប់បានកំណត់[82]។ អត្រាការប្រាក់ដែលច្បាប់បានកំណត់គឺ៥% ក្នុងមួយឆ្នាំ[83]។

### ២.៣. អត្រាការប្រាក់យឺតយ៉ាវ

#### ២.៣.១.ករណីមានការព្រមពៀង

ក្នុងករណីមានការព្រមពៀង ត្រូវអនុលោមតាមការព្រមព្រៀង។ ភាគីអាចព្រមព្រៀងដូចតទៅ៖

- យកអត្រាការប្រាក់ដែលច្បាប់បានកំណត់ យកទាបជាងអត្រាការប្រាក់ដែលច្បាប់បានកំណត់
- យកលើសពីអត្រាការប្រាក់ដែលច្បាប់បានកំណត់។

  ក្នុងករណីភាគីព្រមព្រៀងយក អត្រាការប្រាក់យឺតយ៉ាវលើសពីអត្រាការប្រាក់ដែលច្បាប់បានកំណត់មិនត្រូវឲ្យលើសពី២៧% ក្នុងមួយឆ្នាំឡើយ[84]។

#### ២.៣.២. ករណីគ្មានការព្រមពៀង

(១) ក្នុងករណីគ្មានការព្រមព្រៀងអំពីអត្រាការប្រាក់យឺតយ៉ាវ ប៉ុន្តែមានការព្រមព្រៀងអំពីអត្រាការប្រាក់ នោះត្រូវអនុវត្តតាមអត្រាការប្រាក់ដែលបានព្រមព្រៀង។ ឧទាហរណ៍ ព្រមព្រៀង កំណត់យកអត្រាការប្រាក់ ១០% ក្នុងមួយឆ្នាំ ប៉ុន្តែមិនបានព្រមព្រៀងគ្នាអំពីអត្រាការប្រាក់យឺតយ៉ាវទេ ក្នុងករណីនេះ គេអាចយកអត្រាការប្រាក់យឺតយ៉ាវតាមអត្រាការប្រាក់គឺ ១០% ក្នុងមួយឆ្នាំ[85]។ ប៉ុន្តែក្នុងករណី អត្រាការប្រាក់តាមកិច្ចសន្យាទាបជាងអត្រាការប្រាក់តាមច្បាប់ គេអាចយកអត្រាការប្រាក់យឺតយ៉ាវតាមច្បាប់បាន។ ឧទាហរណ៍ ព្រមព្រៀងយក

---

[80] មាត្រា ៥៨៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី និង មាត្រា ១៧ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

[81] ប្រការ ១ នៃប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត

[82] មាត្រា៥៨៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

[83] មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី

[84] ប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត

[85] មាត្រា ៣៣៩ នៃក្រមរដ្ឋប្បវេណី

អត្រាការប្រាក់ ៣% ក្នុងមួយឆ្នាំ ប៉ុន្តែមិនបានព្រមព្រៀងអំពីអត្រាការប្រាក់យឺតយ៉ាវទេ ក្នុងករណីនេះអត្រាការប្រាក់យឺតយ៉ាវត្រូវយកតាមច្បាប់ ៥% ក្នុងមួយឆ្នាំ[86]។

(២) ក្នុងករណីគ្មានការព្រមព្រៀងអំពីអត្រាការប្រាក់យឺតយ៉ាវ និងគ្មានការព្រមព្រៀងអំពីអត្រាការប្រាក់ អត្រាការប្រាក់យឺតយ៉ាវ ត្រូវអនុលោមតាមច្បាប់[87]។

**២.៣.៣. រយៈពេលនៃប្រាក់កម្ចី៖** រយៈពេលនៃប្រាក់កម្ចីវាយូរ ឬឆាប់វាអាស្រ័យទៅលើតម្រូវការ និងដំណើរការរបស់ម្ចាស់ គម្រោងអភិវឌ្ឍន៍អចលនវត្ថុ និងជាពិសេសរយៈកម្ចីត្រូវបានឯកភាពដោយភាគីទាំងសងខាងដូចមាននូវក្នុងកំណត់កិច្ចសន្យា។

**២.៣.៤. គោលបំណងនៃការប្រើប្រាស់កម្ចី៖** គោលបំណងនៃការប្រើប្រាស់កម្ចីត្រូវបានរាប់បញ្ចូលនៅក្នុងលក្ខខណ្ឌមួយនៅក្នុងកិច្ចសន្យាឥណទាន។ គោលបំណងនេះគ្រាន់តែជាការកំណត់ឡើងវិញឲ្យសមស្របទៅនឹងការស្នើសុំកម្ចី ហើយវាក៏បង្ហាញផងដែរ អំពីចំណាត់ថ្នាក់នៃប្រភេទកម្ចីនីមួយៗ។

**២.៣.៥. របៀបនៃការសង៖** របៀបនៃការសងប្រាក់កម្ចីត្រូវបានធ្វើឡើងដោយបង់ការប្រាក់ប្រចាំខែ និងបង់រំលោះប្រាក់ដើមទៅតាមរយៈពេលយូរ ឬឆាប់អាស្រ័យលើការចែងក្នុងកិច្ចសន្យា។ មានន័យថារបៀបសងប្រាក់កម្ចីមានការកំណត់សងផ្សេងៗគ្នា អាស្រ័យលើការព្រមព្រៀងរបស់គូភាគី។

**២.៣.៦. សោហ៊ុយនៃការធ្វើកិច្ចសន្យា៖** ជាគោលការណ៍សោហ៊ុយចំណាយលើកិច្ចសន្យាអាស្រ័យលើការព្រមព្រៀង។ ក្នុងករណីគ្មានការព្រមព្រៀងសោហ៊ុយនៃកិច្ចសន្យាត្រូវបានសន្មតថាចេញស្មើគ្នា។

**២.៣.៧.កិច្ចសន្យារណប៖** នៅក្នុងការផ្តល់កម្ចីនូវទំហំទឹកប្រាក់ច្រើន ជាពិសេសនៅក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុការបង្កើតនូវកិច្ចសន្យារណប ដែលជាកិច្ចសន្យាបង្កើតប្រាតិភោគដើម្បីធានាអនុវត្តកាតព្វកិច្ចចម្បងដែលជាកិច្ចសន្យាឥណទាន គឺមានភាពចាំបាច់បំផុតក្នុងការបង្ការហានិភ័យ និងស្តារបំណុល។

ការអនុវត្តគ្រប់ធនាគារសុទ្ធសឹងតែចែងអំពី កិច្ចសន្យារណបនេះក្នុងគោលបំណងធានាបាននូវសុវត្ថិភាពក្នុងការគ្រប់គ្រង និងទប់ស្កាត់បាននូវរាល់ការចាត់ចែងទាំងឡាយរបស់កូនបំណុល អាចនឹងប៉ះពាល់ដល់ប្រសិទ្ធិភាពនៃការប្រមូលបំណុល។

[86] មាត្រា ៣៣៩ នៃក្រមរដ្ឋប្បវេណី

[87] មាត្រា ៣៣៩ នៃក្រមរដ្ឋប្បវេណី

**២.៣.៨. យន្តការនៃការដោះស្រាយបំណុល៖** ជាយន្តការដែលអនុញ្ញាតឲ្យធនាគារប្រើប្រាស់សិទ្ធិក្នុងការផាកពិន័យពេលមានការអនុវត្តកាតព្វកិច្ចមានភាពយឺតយ៉ាវ និងអនុញ្ញាតឲ្យធនាគារប្រើប្រាស់សិទ្ធិដើម្បីរឹបអូសទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃ ប្រាតិភោគតាមផ្លូវតុលាការបាន។

**២.៣.៩. វិសាលភាពនៃច្បាប់ដែលត្រូវអនុវត្ត៖** វាជាការកំណត់សមត្ថកិច្ចក្នុងការដោះស្រាយវិវាទដោយផ្អែកលើច្បាប់ដែលមានវិសាលភាព ក្នុងការអនុវត្តនៅក្នុងដែនសមត្ថកិច្ចនៃទីកន្លែងដែលកិច្ចសន្យាត្រូវបានកើតឡើង។ រាល់វិវាទទាំងឡាយដែលកើតចេញពីទំនាក់ទំនងកិច្ចសន្យាគឺ ត្រូវស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាហើយ នឹងត្រូវបញ្ជូនទៅតុលាការដែលមានសមត្ថកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## កថាខណ្ឌ ទី២៖ ប្រាតិភោគ

សិទ្ធិប្រាតិភោគត្រូវបានបង្កើតឡើង ក្នុងនាមជាកិច្ចសន្យារណបទៅនឹងកិច្ចសន្យាចម្បងដែលជាកិច្ចសន្យាឥណទាន ឬកិច្ចសន្យាខ្ចីបរិភោគ។ ផ្អែកតាមក្រមរដ្ឋប្បវេណីមានប្រាតិភោគពីរប្រភេទ ដែលអនុញ្ញាតឲ្យធ្វើជាមធ្យោបាយក្នុងការធានានូវការសងកាតព្វកិច្ចរបស់កូនបំណុល គឺប្រាតិភោគប្រត្យក្ស និង ប្រាតិភោគបុគ្គល។

### ១. ប្រាតិភោគប្រត្យក្ស

ពិតមែនក្រមរដ្ឋប្បវេណីបានបញ្ញត្តិពីប្រាតិភោគចំនួនប្រាំរួមមាន៖ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក ឯកសិទ្ធិ សិទ្ធិឃាត់ទុក និងសិទ្ធិប្រាតិភោគដោយអនុប្បទាន ក្រៅពីនេះមានប្រភេទនៃប្រតិបត្តិការដែលមានកិច្ចធានា កំណត់ដោយច្បាប់ឆ្នាំ២០០៧ ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាជាដើម តែយើងនឹងធ្វើការបកស្រាយជាសំខាន់នៅទីនេះ តែលើប្រធានបទនៃយន្តការប្រាតិភោគប្រត្យក្សមាន ហ៊ីប៉ូតែក និងសិទ្ធិលើការបញ្ចាំ ដែលជាជម្រើសពេញនិយមសម្រាប់វិស័យហិរញ្ញប្បទាន យើងនឹងវិនិច្ឆ័យលើទិដ្ឋភាពច្បាប់ និង ការការពារហានិភ័យនៃការសង។

ហ៊ីប៉ូតែក និងការបញ្ចាំ គឺជាប្រាតិភោគប្រត្យក្សលើអចលនវត្ថុកើតចេញពីឆន្ទៈរបស់ភាគីពោលគឺត្រូវបង្កើតឡើងតាមរយៈកិច្ចសន្យាប្រាតិភោគមួយអាចជាកិច្ចសន្យាហ៊ីប៉ូតែក ឬកិច្ច-សន្យាបង្កើតសិទ្ធិលើការបញ្ចាំជាដើម។ មិនខុសពីកិច្ចសន្យាក្នុងនីតិរួមនោះទេ កិច្ចសន្យាត្រូវមានការព្រមព្រៀងពិតប្រាកដដោយបុគ្គល ដែលមានសមត្ថភាពពេញលេញស្របតាមការ

កំណត់របស់ច្បាប់ជាធរមាន។ មាត្រា៨៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ជាក់ពីប្រភេទកម្មវត្ថុ និងសិទ្ធិជួលអចិន្ត្រៃយ៍ផលុបភោគជាដើម។ មាត្រា៨៤៥ នៃក្រមនេះក៏បញ្ជាក់ពីលក្ខខណ្ឌបង្កើតកិច្ចសន្យានេះ ដោយមានលក្ខខណ្ឌសុពលភាព និងលក្ខខណ្ឌតតាំង។ លក្ខខណ្ឌសុពលភាព គឺមានត្រឹមតែការព្រមព្រៀងរបស់គូភាគីជាការស្រេច គឺការព្រមព្រៀងរវាងអ្នកបង្កើតហ៊ីប៉ូតែក និងម្ចាស់បំណុលហ៊ីប៉ូតែក។ ចំណែកលក្ខខណ្ឌតតាំងសំដៅដល់ការតតាំងប្រឆាំងនឹងតតីយជនដែលមានបំណងចែងលើអចលនវត្ថុដែលជាកម្មវត្ថុហ៊ីប៉ូតែក តម្រូវឲ្យចុះបញ្ជី និងធ្វើជាទម្រង់លិខិតយថាភូត។

## ២.ប្រាតិភោគបុគ្គល

ចំពោះការបង្កើតកិច្ចសន្យា ធ្វើឡើងដោយការបង្ហាញឆន្ទៈព្រមព្រៀងគ្នារវាងបុគ្គលដែលមានបំណងធ្វើជាអ្នកធានា និងម្ចាស់បំណុល ដោយសន្យាជាមួយម្ចាស់បំណុលថា ខ្លួនអនុវត្តកាតព្វកិច្ចមួយផ្នែក ឬទាំងមូលជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បង ប្រសិនបើកូនបំណុលមានកាតព្វកិច្ចចម្បងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប៉ុន្តែភាគីអាចធ្វើការព្រមព្រៀងផ្សេងនេះបាន ដោយអ្នកធានាទទួលបន្ទុកកាតព្វកិច្ច ធានាឯករាជ្យភាពពីកាតព្វកិច្ចចម្បងដោយមានអនុវត្តចំពោះអាជីវកម្មជាការធានាជាដើម។ ករណីដែលអ្នកធានាជាបុគ្គលធម្មតាម្ចាស់បំណុលត្រូវផ្តល់ព័ត៌មានគ្រប់គ្រាន់ដើម្បីអាចឲ្យអ្នកធានាយល់ដឹង និងពិចារណាឲ្យបានហ្មត់ចត់នៅក្នុងបន្ទុកនៃការធានា។ ជាគោលការណ៍ ការធានាទាំងឡាយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចំនួនទឹកប្រាក់នៃកិច្ចធានាត្រូវសរសេរដោយផ្ទាល់ដៃរបស់អ្នកធានា ក្នុងករណីអនុវត្តកាតព្វកិច្ចមានគោលការបំណងសងជាប្រាក់ និងបញ្ជាក់ឲ្យបានច្បាស់លាស់អំពីខ្លឹមសារនៃកាតព្វកិច្ចធានា បើមិនដូច្នេះទេ អ្នកធានាអាចដកការធានានៅពេលណាក៏បាន តែករណីមិនអនុវត្តទេ កាលបើអ្នកធានាចាប់ផ្តើមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត។

ចំពោះអានុភាពនៃការធានា គឺអ្នកធានាទទួលខុសត្រូវចំពោះកាតព្វកិច្ចចម្បង ព្រមទាំងកាតព្វកិច្ចបន្ទាប់បន្សំដែលកើតឡើងដោយកាតព្វកិច្ចចម្បងនោះ ហើយទំហំនៃកាតព្វកិច្ចនេះគឺអនុវត្តតាមការបង្ហាញឆន្ទៈភាគីក្នុងកិច្ចសន្យា ឬកាតព្វកិច្ចបន្ទាប់បន្សំដែលអាចមានគឺៈ ការប្រាក់ ឬប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ឬអាចមានសំណងខូចខាតដទៃទៀត ហើយកាតព្វកិច្ចនេះ ជាទូទៅត្រូវមានកំណត់ជាមុន និងជាក់លាក់។ អានុភាពដ៏សំខាន់មួយទៀត នៃកិច្ចសន្យាធានាគឺ កាតព្វកិច្ចសាមគ្គី។

នៅពេលដែលប្រាតិភោគត្រូវបានបំពេញរួចរាល់ចប់សព្វគ្រប់ ទើបធនាគារប្រគល់ប្រាក់កម្ចីទៅឲ្យម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ។

## ជំពូកទី ២៖ ការអនុវត្តកិច្ចសន្យាហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ

## ផ្នែកទី១៖ សិទ្ធិ និង កាតព្វកិច្ចរបស់ម្ចាស់គម្រោង

### កថាខណ្ឌទី១. សិទ្ធិរបស់ម្ចាស់គម្រោង

ក្នុងនាមជាភាគីនៃកិច្ចសន្យាហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ តើម្ចាស់គម្រោងមានសិទ្ធិអ្វីខ្លះតាមទំនាក់ទំនងកិច្ចសន្យាដែលបានបង្កើតឡើងជាមួយនឹងធនាគារ?

#### ១. សិទ្ធិជាគោលការណ៍គ្រឹះពាក់ព័ន្ធនឹងកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់

ផ្អែកតាមមាត្រា៥៨៧កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីបានអនុញ្ញាតឲ្យអ្នកខ្ចី (ម្ចាស់គម្រោងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ) ក្នុងការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដោយសេរីចំពោះវត្ថុដែលជាកម្មវត្ថុ។ លើសពីនេះទៅទៀត អ្នកខ្ចីក៏មានសិទ្ធិរំលាយកិច្ចសន្យាផងដែរ ប្រសិនបើអ្នកខ្ចីមិនអាចអនុវត្ត កាតព្វកិច្ចរបស់ខ្លួនបាន។

នៅក្នុងទិដ្ឋភាពច្បាប់សារធាតុជាធរមានក៏បានអនុញ្ញាតផងដែរ នូវសិទ្ធិក្នុងការទាមទារសំណងការខូចខាត ក្នុងករណីដែលអ្នកខ្ចី(ម្ចាស់គម្រោងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ) ទទួលបានការប្រគល់នូវប្រាក់ដែលមិនមែនជាកម្មសិទ្ធិរបស់អ្នកឲ្យខ្ចី។[88]

#### ២. សិទ្ធិរបស់ម្ចាស់គម្រោងនៅក្នុងទិដ្ឋភាពនៃការអនុវត្តជាក់ស្ដែង

នៅក្នុងក្របខ័ណ្ឌនៃការទទួលបានហិរញ្ញប្បទានអចលនវត្ថុ តាមរយៈធនាគារមានភាពខុសគ្នាច្រើនពីគោលការណ៍ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី។ ក្នុងការអនុវត្តជាក់ស្ដែងគេឃើញមាន ការកំណត់សិទ្ធិជាអប្បបរមាដូចខាងក្រោម៖

#### ២.១. សិទ្ធិទទួលបានហិរញ្ញប្បទាននូវលក្ខខណ្ឌដែលបានព្រមព្រៀង

ក្រោយពីកិច្ចសន្យាឥណទានត្រូវបានបង្កើតឡើង កិច្ចសន្យាប្រាតិភោគត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី និងឯកសារផ្លូវច្បាប់ផ្សេងទៀតត្រូវបានបំពេញ ម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុមានសិទ្ធិទទួលបានូវហិរញ្ញប្បទាននៅទីកន្លែង និងពេលវេលាទៅតាមការកំណត់នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា។ មានន័យថាសិទ្ធិស្របច្បាប់ក្នុងទាមទារនូវ

[88] មាត្រា ៥៨៨ កថាខណ្ឌ៣ នៃក្រមរដ្ឋប្បវេណី

ហិរញ្ញប្បទានត្រូវបានបង្កើតឡើងដោយអត្ថិភាពនៃកិច្ចសន្យា។ ក្នុងករណីមិនអនុវត្តកាតព្វកិច្ចម្ចាស់គម្រោងអាចទាមទារសុំរំលាយកិច្ចសន្យា និង ទាមទារសំណងជំងឺចិត្តបានពីធនាគារ។[89]

### ២.២. សិទ្ធិសុំបន្ថយអត្រាការប្រាក់ដោយផ្អែកការប្រែប្រួលផ្នែកអាជីវកម្ម

ការបង្កើតកិច្ចសន្យាគួរតែមានផ្តល់នូវ សមភាពខាងលទ្ធភាពហិរញ្ញវត្ថុជាពិសេសក្នុងស្ថានភាព ឬកាលៈទេសៈនៃការប្រែប្រួលខាងសេដ្ឋកិច្ច ដើម្បីអនុញ្ញាតឲ្យមានការចរចាឡើងវិញក្នុងបន្ថយនូវអត្រាការប្រាក់ ដើម្បីសម្របសម្រួលដល់ដំណើរការនៃអាជីវកម្មរបស់ក្រុមហ៊ុនដែលជាម្ចាស់គម្រោង។ ដូច្នេះការចែងជាខនៅក្នុងកិច្ចសន្យាអំពីលទ្ធភាពនៃការបើកឲ្យមានសិទ្ធិក្នុងការសុំបន្ថយអត្រាការប្រាក់ក្នុងការប្រែប្រួលស្ថានការអាជីវកម្មដោយ សារឥទ្ធិពលនៃបរិយាកាសសេដ្ឋកិច្ច គឺជាលក្ខខណ្ឌចាំបាច់មួយក្នុងការធានាបាននូវដង្ហើមរស់របស់ក្រុមហ៊ុន។

### ២.៣. សិទ្ធិសងកាតព្វកិច្ចមុនកាលកំណត់

អត្ថិភាពនៃអាជីវកម្មមិនអាចធានាបានថា មានស្ថិរភាពជារៀងរហូតឡើយ ព្រោះនឹងអាចមានបរិយាកាសអាជីវកម្មអំណោយផលផ្សេងទៀត ដែលអនុញ្ញាតឲ្យម្ចាស់អាជីវកម្មងាកទៅរកការធ្វើអាជីវកម្មថ្មី។ ដើម្បីគិតគូរដល់អាជីវកម្មថ្មីនោះ វាមានភាពចាំបាច់ក្នុងការសងកាតព្វកិច្ចដែលខ្លួនមានចំពោះធនាគារដែលត្រូវបានឲ្យឈ្មោះថាការសងកាតព្វកិច្ចមុនកាលកំណត់។

ការជ្រើសរើសអាជីវកម្មគឺជាសិទ្ធិរបស់បុគ្គលគ្រប់រូប តែការសងកាតព្វកិច្ច វាជាកាតព្វដែលត្រូវធ្វើ។ ដើម្បីអនុញ្ញាតឲ្យមានការសងកាតព្វកិច្ចមុនកាលកំណត់ ការបង្កើតលក្ខខណ្ឌនៅក្នុងកិច្ចសន្យានឹងបង្ហាញឲ្យឃើញភាពចាំបាច់មួយផងដែរ។ ក៏ប៉ុន្តែដើម្បីធានានូវសមភាពនូវផលប្រយោជន៍របស់ភាគី ការចែងអំពីខពិន័យក្នុងការសងមុននូវកាតព្វកិច្ចត្រូវបានយកមកពិចារណាផងដែរ។

## កថាខណ្ឌទី២.កាតព្វកិច្ចរបស់ម្ចាស់គម្រោង

តើម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុត្រូវអនុវត្តកាតព្វកិច្ចអ្វីខ្លះចំពោះទំនាក់ទំនងនៃកិច្ចសន្យាដែលបានបង្កើតឡើង?

### ១.កាតព្វកិច្ចតាមការកំណត់នៅក្នុងក្រមរដ្ឋប្បវេណី

នៅក្នុងក្របខណ្ឌច្បាប់ជាធរមាននៃក្រមរដ្ឋប្បវេណីដែលចែងពីការខ្ចីបរិភោគដែលមានការប្រាក់បានកំណត់នូវកាតព្វកិច្ចចម្បងរបស់អ្នកខ្ចីដូចជា៖

[89] មាត្រា៤០៧ នៃក្រមរដ្ឋប្បវេណី

### ១.១. ករណីយកិច្ចត្រូវសងប្រាក់ដើម និង បង់ការប្រាក់

ករណីកិច្ចត្រូវសង គឺជាករណីកិច្ចចម្បង និងទូទៅបំផុតរបស់អ្នកខ្ចី ហើយករណីកិច្ចនេះ គឺត្រូវបំពេញឲ្យបាននៅពេលដែលពេលវេលាកំណត់ នៃការសងបានមកដល់មិនតែប៉ុណ្ណោះ ការសងត្រូវធ្វើឡើងដោយគោរពតាមគោលការណ៍មួយចំនួន[90]។ អ្នកខ្ចីមិនអាចសងនូវវត្ថុដែលមានបរិមាណតិចជាង ហើយអ្នកឲ្យខ្ចីក៏មិនអាចទាមទារឲ្យអ្នកខ្ចីផ្តល់នូវការសងវត្ថុដែលមានបរិមាណច្រើនជាង បរិមាណដែលបានកំណត់ក្នុងកិច្ចសន្យានោះទេ លើកលែងតែភាគីទាំងពីរបានព្រមព្រៀងគ្នា។ ប្រសិនបើការសងមិនបានបំពេញគ្រប់លក្ខ-ខណ្ឌដែលបានកំណត់ដូចខាងលើនោះទេ អ្នកឲ្យខ្ចីអាចបដិសេធមិនទទួលយកនូវការសងដោយមូលហេតុណាមួយដូចជា ភាពខុសគ្នានៃប្រភេទ ឬបរិមាណ ឬគុណភាព ហើយអ្នកឲ្យខ្ចីអាចទាមទារឲ្យអ្នកខ្ចីទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ។

### ១.២. ពេលវេលានៃការសង

អ្នកឲ្យខ្ចីមិនអាចទាមទារឲ្យអ្នកខ្ចីសងកាតព្វមុនកាលកំណត់បានឡើយ[91]។ ប៉ុន្តែក៏នៅមានករណីលើកលែងមួយចំនួន ដែលអាចឲ្យអ្នកឲ្យខ្ចីទាមទារឲ្យសងមុនកាលកំណត់បានដូចជាៈ ករណីដែលអ្នកខ្ចីត្រូវបានប្រកាសក្ស័យធន កូនបំណុលបានធ្វើឲ្យខូចខាតប្រាតិភោគ (វត្ថុធានាបំណុល) កូនបំណុលមានករណីកិច្ចត្រូវដាក់ប្រាតិភោគ។ ប៉ុន្តែខ្លួនមិនបានបំពេញករណីយកិច្ចនេះ ឬហេតុដែលគូភាគីបានព្រមព្រៀងគ្នាបានកើតឡើង[92]។

## ២. កាតព្វកិច្ចនៅក្នុងទិដ្ឋភាពនៃការអនុវត្តជាក់ស្តែង

### ២.១. បង់ការប្រាក់ទាន់ពេលវេលាដែលបានកំណត់

កាតព្វកិច្ចចម្បង និងសំខាន់ជាងគេគឺកាតព្វកិច្ចក្នុងការបង់ការប្រាក់ជូនធនាគារតាមការកំណត់ទៅពេលតាមវេលា និងទីកន្លែងដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យា។ ការអនុវត្តកាតព្វកិច្ចនេះ វាបង្ហាញអំពីភាពស្មោះត្រង់របស់ម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ ហើយវាក៏បង្ហាញផងដែរ អំពីការបង្កើតឲ្យមានកេរ្តិ៍ឈ្មោះល្អដើម្បីទទួលបានហិរញ្ញប្បទាននាពេលក្រោយៗទៀត។ ការបង់ការប្រាក់យឺតយ៉ាវ គួរតែត្រូវបានបង្ហាញនូវហេតុផលសមរម្យក្នុងពេលវេលា

---

[90] មាត្រា ៥៩១ រហូតដល់ មាត្រា ៥៩៥ នៃក្រមរដ្ឋប្បវេណី

[91] មាត្រា ៥៩៤ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី

[92] មាត្រា ៣៣១ នៃក្រមរដ្ឋប្បវេណី

សមស្របមួយ ហើយត្រូវបង្ហាញឲ្យឃើញនូវភាពស្មោះត្រង់។ លក្ខខណ្ឌសមស្របនេះគួរតែចែងនៅក្នុងខនៃកិច្ចសន្យាដើម្បីធានាបាននូវទំនាក់ទំនងល្អផង និងរក្សាបាននូវស្ថេរភាពអាជីវកម្មរបស់ខ្លួនផង។

ក្នុងការអនុវត្តជាក់ស្តែងលក្ខខណ្ឌនេះហាក់ដូចជា ពុំឃើញមានចែងអំពី សមភាពនេះណាស់ ដោយហេតុថា តែងតែពុំមានសមភាពរវាងគូភាគី។ ផ្ទុយមកវិញកិច្ចការការពាររបស់ធនាគារ វាមានវិសាលភាពធំជាងកិច្ចការការពាររបស់ម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ។ ហេតុអ្វីបានជាខនៃកិច្ចសន្យារបស់ធនាគារភាគច្រើនជាកំណត់ ដោយធនាគារជាជាងឲ្យមានការចរចារបស់ម្ចាស់គម្រោង ឬក៏អ្នកខ្ចី? ព្រោះថាហិរញ្ញប្បទានិក ដែលជាធនាគារចង់បញ្ចៀសរាល់ហានិភ័យដែលអាចនឹងកើតឡើងនាពេលអនាគត។ តម្លៃតបស្នងនៃការអនុវត្តកាតព្វកិច្ចនៃការសងមិនត្រូវបានអនុវត្តតែមួយពេលហើយបញ្ចប់នោះឡើយ គឺកូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនទៅតាមពេលវេលា ហើយធនាគារមិនអាចធ្វើការទស្សន៍ទាយបាននូវស្ថានភាពហិរញ្ញវត្ថុរបស់ម្ចាស់គម្រោង ឬ កូនបំណុល។

### ២.២. ប្រើប្រាស់ហិរញ្ញប្បទានឲ្យចំទិសដៅនៃគម្រោង

ម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុត្រូវប្រើប្រាស់នូវហិរញ្ញប្បទានដោយ ធនាគារឲ្យចំទិសដៅ និងមានប្រសិទ្ធិភាព។ ការប្រើប្រាស់ហិរញ្ញប្បទានខុសពីគោលបំណង និងក្លាយជាមូលហេតុនៃការអនុវត្តកាតព្វកិច្ចមិនត្រឹមត្រូវដែលអនុញ្ញាតឲ្យភាគី នៃធនាគារសុំឲ្យបង់ផ្តាច់ប្រាក់កម្ចីភ្លាមដោយមានការពិន័យជាភាគរយធៀបទៅនឹងកម្ចីសរុបទាំងមូល។ កាតព្វកិច្ចនេះមានវិសាលភាពអនុវត្តធំធេងផងដែរ ដោយហេតុថា ហិរញ្ញប្បទានដែលយកទៅប្រើប្រាស់ក្នុងគម្រោងអាជីវកម្មបានជោគជ័យ ក៏វាផ្តល់ភាពងាយស្រួលដល់ការសងត្រលប់នូវកម្ចីជូនមកធនាគារវិញ ដោយគ្មានហានិភ័យផងដែរ។ ម្យ៉ាងវិញទៀតការប្រើប្រាស់ហិរញ្ញប្បទានមានប្រសិទ្ធិភាព និងធ្វើឲ្យការសងកាតព្វកិច្ចមានស្ថិរភាព និងធ្វើឲ្យទំនាក់ទំនងផលប្រយោជន៍រវាងភាគីបន្តអត្ថិភាពបានយូរអង្វែង និងរីកចម្រើន។

### ២.៣. អនុវត្តកាតព្វកិច្ចរបស់ខ្លួនឲ្យមានតម្លាភាព និង ស្មោះត្រង់

ម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុមិនត្រឹមតែប្រើប្រាស់ នូវហិរញ្ញប្បទានឲ្យចំទិសដៅ ប៉ុន្តែត្រូវអនុវត្តផងដែរឲ្យសមស្របទៅតាមច្បាប់ និងអនុវត្តកាតព្វកិច្ចផ្សេងៗទៀតឲ្យបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋ ដូចជា កាតព្វកិច្ចក្នុងការបង់ពន្ធជូនរដ្ឋ ការសហការល្អជាមួយស្ថាប័ន

រដ្ឋជុំវិញការប្រយុទ្ធប្រឆាំងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម[93]។ ការអនុវត្តកាតព្វ-កិច្ចឲ្យមានតម្លាភាព និងស្មោះត្រង់មិនត្រឹមតែបង្ហាញឲ្យឃើញពីភាពស្មោះត្រង់របស់ខ្លួនចំពោះធនាគារទេតែវាបានបង្ហាញផងដែរ អំពីសកម្មភាពអាជីវកម្មដែលមានភាពស្មោះត្រង់ ចំពោះរដ្ឋក្នុងការចូលរួម ក្នុងការអភិវឌ្ឍន៍កសាង ល័ក្ខខ័ណ្ឌជីវិតរស់នៅ ការរីកចម្រើនខាងផ្នែក សេដ្ឋកិច្ចសង្គមកិច្ច និងធានាបាននូវការគាំពារខាងផ្នែកច្បាប់ពីរដ្ឋ។

## ផ្នែកទី២ ៖ សិទ្ធិ និង កាតព្វកិច្ចរបស់ហិរញ្ញប្បទានិក

### កថាខណ្ឌទី១. សិទ្ធិ របស់ហិរញ្ញប្បទានិក

ដូចដែលបានលើកឡើងពីខាងលើធនាគារដើម្បីបង្ការនូវហានិភ័យ ការចែងនៅក្នុងកិច្ចសន្យាតែងបង្កើតនូវសិទ្ធិលើសលប់ចំពោះម្ចាស់គម្រោង។ ខាងក្រោមនេះគឺជាការបង្ហាញឲ្យឃើញនូវសិទ្ធិសំខាន់ៗរបស់ធនាគារ៖

១.សិទ្ធិតាមការកំណត់ក្នុងក្រមរដ្ឋប្បវេណី

១.១. សិទ្ធិរំលាយកិច្ចសន្យាដោយស្ថានភាពសេដ្ឋកិច្ចអ្នកខ្ចីធ្លាក់ចុះ

នៅពេលកិច្ចសន្យាខ្ចីបរិភោគបានបង្កើតឡើងរវាងអ្នកឲ្យខ្ចី និងអ្នកខ្ចី ហើយស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីក្នុងការអនុវត្តកាតព្វកិច្ចសងក្លាយជាមានឧបសគ្គ នៅមុនពេលប្រគល់វត្ថុអ្នកឲ្យខ្ចីអាចរំលាយកិច្ចសន្យានោះបាន[94]។ ស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីក្នុងការអនុវត្តកាតព្វកិច្ចសងក្លាយទៅជាឧបសគ្គមានដូចជាៈ ដែលកូនបំណុល(អ្នកខ្ចី) ត្រូវបានប្រកាសក្ស័យធន កូនបំណុលបានធ្វើឲ្យខូចខាតដល់ប្រាតិភោគ(វត្ថុធានាបំណុល) កូនបំណុលមានករណីយកិច្ចត្រូវដាក់ប្រាតិភោគ ប៉ុន្តែខ្លួនមិនបានបំពេញករណីយកិច្ចនេះ ឬហេតុដែលគូភាគីបានព្រមព្រៀងគ្នាបានកើតឡើង។

១.២. សិទ្ធិតម្លើងការប្រាក់ ឬបន្ថយការប្រាក់ដោយផ្អែកលើការប្រែប្រួលរបស់សេដ្ឋកិច្ចជាតិ ឬ អន្តរជាតិ

ហេតុអ្វីបានជាធនាគារមានសិទ្ធិក្នុងការតម្លើងការប្រាក់ ឬបន្ថយការប្រាក់នៅពេលមានការប្រែប្រួលសេដ្ឋកិច្ចជាតិ និងអន្តរជាតិដូចជា វិបត្តិផ្នែកហិរញ្ញវត្ថុ អតិផរណាជាដើម តែងជះឥទ្ធិពលដល់ការធ្វើចរាចរណ៍មូលធនរបស់ធនាគារ។ នៅក្នុងបរិបទសេដ្ឋកិច្ចទីផ្សារសេរីមាន

---

[93] គោលការណ៍ប្រឆាំងការសំអាតការប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម(ធនាគារអេស៊ីដា) ថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០០២

[94] មាត្រា ៥៨១ នៃក្រមរដ្ឋប្បវេណី

ការបើកឲ្យមានការប្រកួតប្រជែងដោយស្មោះត្រង់ ហើយយើងឃើញថាការបង្កើតធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកំពុងមានការរីកដុះដាលដូចផ្សិត។ នៅពេលដែលមានជួបនៅការប្រែប្រួលខាងផ្នែកសេដ្ឋកិច្ចគឺ ជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ការប្រកួតប្រជែងផងដែរ ឧទាហរណ៍ ពេលមានវិបត្តិសេដ្ឋកិច្ចធនាគារនីមួយៗ ព្យាយាមបញ្ចុះអត្រាការប្រាក់របស់ខ្លួនដើម្បីទាក់ទាញអតិថិជនដើម្បីមកទទួលនូវសេវាហិរញ្ញប្បទាន។ ផ្ទុយមកវិញនោះនៅពេលដែលសេដ្ឋកិច្ចជាតិមានការលូតលាស់គ្រប់វិស័យដូចជា ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ជាពិសេសអាជីវកម្មលើអចលនវត្ថុ នឹងបង្កើតបានជាកាលានុវត្តភាពសម្រាប់ម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ ហើយក៏ជាកាលានុវត្តភាពសម្រាប់ធនាគារផងដែរ ក្នុងការតម្លើងនូវអត្រាការប្រាក់។ តែទោះជាយ៉ាងណាក្នុងស្ថានភាពមួយដែលមិនអាចស្តារស្ថានភាពនៃ ការធ្លាក់ចុះខ្លាំងពេកនៃសេដ្ឋកិច្ចនោះនឹងមានការចូលអន្តរាគមន៍ពីរដ្ឋ។ តើការតម្លើង និងបន្ថយអត្រាការប្រាក់វាបានជះឥទ្ធិពលយ៉ាងដូចម្តេចដល់ម្ចាស់អភិវឌ្ឍន៍អចលនវត្ថុ?

វាបានប៉ះពាល់ដល់ការសងត្រលប់មកវិញ របស់ម្ចាស់គម្រោងអភិឌ្ឍន៍អចលនវត្ថុ។ ក្នុងលក្ខខណ្ឌនៃការប្រែប្រួលសេដ្ឋកិច្ច វាជាស្ថានភាពមួយសមហេតុផលដែលធនាគារប្រើប្រាស់សិទ្ធិរបស់ខ្លួន។ ផ្ទុយមកវិញក្នុងករណីដែលមានស្ថិរភាពផ្នែកសេដ្ឋកិច្ចវានឹងពុំសមហេតុផលឡើយ បើធៀបទៅនឹងសមភាពនៃផលប្រយោជន៍របស់ម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ។ ទោះជាយ៉ាងណាក្នុងស្ថានភាពនេះអាចទទួលយកបាន ក្នុងករណីមានការព្រមព្រៀងគ្នា ព្រោះវាជាស្វ័យឆន្ទៈរបស់បុគ្គលឯកជនដូចមានចែងក្នុងក្រមរដ្ឋប្បវេណី[95]។

### ១.៣. តាមដាន និង វាយតម្លៃអំពីដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន

ការតាមដាន និងវាយតម្លៃអំពីដំណើរអាជីវកម្មរបស់ក្រុមហ៊ុនក៏វាមានសារៈសំខាន់ផងដែរ ព្រោះវាជាការត្រួតពិនិត្យ និង តាមដានការប្រើប្រាស់នូវហិរញ្ញប្បទានត្រឹមត្រូវទៅតាមគម្រោងនេះដែរឬទេ។ លើសពីនេះទៅតើដំណើរការអាជីវកម្មនោះប្រព្រឹត្តទៅល្អប្រសើរដែរឬទេ ឬថាតើអាចប្រឈមនឹងការក្ស័យធនទេ។ សិទ្ធិ និងការតាមដាននេះពិតជាមានសារៈសំខាន់ក្នុងការវាស់វែងអំពីលទ្ធភាព សងរបស់ម្ចាស់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ។

ជាគោលការណ៍ទូទៅ ធនាគារតាមដានរបាយការណ៍ចុងឆ្នាំរបស់ក្រុមហ៊ុនអភិវឌ្ឍន៍អចលនវត្ថុ ប៉ុន្តែការពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុនេះមានធនាគារខ្លះយកពិនិត្យ និងធនាគារខ្លះទៀតមិនធ្វើការពិនិត្យទេ។ នៅកម្ពុជាមានការយោគយល់ច្រើន ព្រោះមិនចង់ធ្វើឲ្យ

95 មាត្រា ៣ នៃក្រមរដ្ឋប្បវេណី

អតិថិជនរបស់ខ្លួនរវល់ច្រើន លើសពីនេះដោយសារមូលហេតុនៃការប្រកួតប្រជែង ទើបធ្វើឲ្យធនាគារនៅកម្ពុជាមិនសូវយកមធ្យោបាយនេះមកប្រើប្រាស់។ ផ្ទុយមកវិញធនាគារនៃកម្ពុជាប្រើប្រាស់ការតាមដានតាមរយៈការវាយតម្លៃអចលនវត្ថុដែលបានដាក់ប្រាតិភោគ ជារៀងរាល់ឆ្នាំដោយប្រៀបធៀបមើលតម្លៃអចលនវត្ថុនាពេលដាក់ប្រាតិភោគ និងតម្លៃនាពេលបច្ចុប្បន្ន។ បើសិនវាយតម្លៃទៅឃើញថាអចលនវត្ថុ នោះមានការថយចុះនោះធនាគារនឹងតម្រូវឲ្យមានការដាក់ប្រាតិភោគបន្ថែម។

### ១.៤. សិទ្ធិក្នុងការពិន័យក្នុងករណីមានមានការសងកាតព្វកិច្ចមុនកាលកំណត់

ភាគច្រើនសិទ្ធិនេះត្រូវបានចងនៅក្នុងខនៃកិច្ចសន្យា ហើយវាដើរតួនាទីសំខាន់ដើម្បីជម្រុញមិនឲ្យគូភាគីអនុវត្តកាតព្វកិច្ចតាមទំនើងចិត្ត។ ក្នុងករណីដែលកូនបំណុលសងកាតព្វ-កិច្ចមុនកាលកំណត់វាធ្វើចរន្តនៃការទូទាត់សាច់ប្រាក់ ឬការទស្សន៍ទាយអំពីប្រាក់ចំណូលរបស់ធនាគារមានការថយចុះ។ ការអនុញ្ញាតឲ្យធនាគារមានសិទ្ធិនេះមានភាពសមរម្យដើម្បីរក្សាបាននូវតុល្យភាពនៃលំហូរសាច់ប្រាក់ក្នុងធនាគារ។

### ១.៥. សិទ្ធិក្នុងការពិន័យក្នុងករណីមានភាពយឺតយ៉ាវក្នុងការអនុវត្តកិច្ច ឬ ការមិនអនុវត្តពេញលេញនូវកាតព្វកិច្ច

ការយឺតយ៉ាវក្នុងការសងកាតព្វកិច្ច ក៏ជាលក្ខខណ្ឌមួយអនុញ្ញាតឲ្យធនាគារប្រើប្រាស់សិទ្ធិ ក្នុងការពិន័យទៅតាមភាគរយសមស្របធៀបទៅនឹងកម្ចីសរុប។ ការប្រើប្រាស់សិទ្ធិនេះគឺក្នុងគោលបំណងជម្រុញឲ្យកូនបំណុលព្យាយាមអនុវត្តត្រឹមត្រូវ ឲ្យបានទៀងទាត់ពេលវេលា និងរក្សាបាននូវការបង្កាហានិភ័យក្នុងការទូទាត់បំណុល និងការចាត់ចែងហិរញ្ញប្បទានដល់អតិថិជនផ្សេងទៀត។ ការសងមុននូវកាតព្វកិច្ចវាជះឥទ្ធិពលដល់ចំណូល និងការព្យាករណ៍ចំណូលរបស់ធនាគារផងដែរ។

### ១.៦. សិទ្ធិស្របច្បាប់ក្នុងការប្តឹងទៅតុលាការដើម្បីរឹបអូសទ្រព្យសម្បត្តិ របស់កូនបំណុលដើម្បីសងបំណុល

សិទ្ធិប្តឹងទៅតុលាការជាសិទ្ធិសំខាន់ដែលជាមធ្យោបាយ ឬយន្តការផ្នែកច្បាប់ដែលអនុញ្ញាតឲ្យធនាគារប្តឹងទៅតុលាការ ដើម្បីលក់ទ្រព្យរបស់កូនបំណុលដោយផ្អែកលើសិទ្ធិលើបំណុល និងសិទ្ធិប្រាតិភោគលើអចលនវត្ថុដើម្បីលក់ឡៃឡុងយកប្រាក់មកសងធនាគារ។ ក្នុងការអនុវត្តជាក់ស្តែង មុននឹងឈានដល់ការប្តឹងទៅតុលាការឲ្យមានការលក់ទ្រព្យសម្បត្តិធនាគារតែងតែរកមធ្យោបាយក្រៅប្រព័ន្ធតុលាការដូចជា មានការដោះស្រាយត្រឹមឃុំសង្កាត់ ស្រុក ខណ្ឌ

និងលុះត្រាណាតែគ្មានដំណោះស្រាយមួយ ដែលអាចទទួលយកបានទើបមានការជ្រើសរើសយកផ្លូវតុលាការជាជម្រើសចុងក្រោយ។ ហេតុអ្វីបានជាធនាគាពេញនិយមក្នុងការដោះស្រាយតាមយន្តការក្រៅប្រព័ន្ធតុលាការជាជាងដោះស្រាយនៅក្នុងតុលាការ? ពីព្រោះចំណេញពេលវេលា ប្រាក់កាស នីតិវិធីមិនស្មុគស្មាញ ចំណែកឯការដោះស្រាយតាមយន្តការតុលាការវិញវាចំណាយនូវថវិកាច្រើន តាមរយៈការចំណាយលើសេវាមេធាវី ខាតពេលវេលាដោយលំហូរនីតិវិធីមានភាពស្មុគស្មាញ និងប្រើរយៈពេលយូរ។

## កថាខណ្ឌទី២.កាតព្វកិច្ចរបស់ហិរញ្ញប្បទានិក

ការបង្កើតនូវហិរញ្ញប្បទានក្នុងការអភិវឌ្ឍន៍គម្រោងអចលនវត្ថុ វាមានលក្ខណៈពិសេសព្រោះវាពាក់ព័ន្ធទំហំសាច់ប្រាក់ច្រើនៗ ទាមទារឲ្យមានការពិចារណាយ៉ាងល្អិតល្អន់គ្រប់ជ្រុងជ្រោយធ្វើយ៉ាងណាការពារឲ្យបាននូវផលប្រយោជន៍ធនាគារក្នុងកម្រិតខ្ពស់បំផុត។ ហេតុនេះហើយនៅក្នុងកិច្ចសន្យាមានការចងនូវលក្ខខណ្ឌទាំងឡាយកំណត់អំពីសិទ្ធិរបស់ធនាគារច្រើនជាអតិបរមា ចំណែកឯការចងលក្ខខណ្ឌជាកាតព្វកិច្ចគឺមានតិចតួចបំផុត។ បើពិនិត្យមើលទៅឃើញមានកាតព្វកិច្ចធំពីរប៉ុណ្ណោះ គឺកាតព្វកិច្ចក្នុងការផ្តល់នូវហិរញ្ញប្បទានតាមការលក្ខខណ្ឌដែលបានព្រមព្រៀង និងការបង្វិលទ្រព្យដែលដាក់ប្រាតិភោគទៅឲ្យកូនបំណុលពេលកាតព្វកិច្ចត្រូវបានសងរួចរាល់។

### ១.ផ្តល់ហិរញ្ញប្បទានតាមការព្រមព្រៀង

នៅពេលដែលលក្ខខណ្ឌបុរេវិនិច្ឆ័យត្រូវបានសិក្សាបញ្ចប់ កិច្ចសន្យាផ្តល់ហិរញ្ញប្បទានត្រូវបានបង្កើត ព្រមទាំងប្រាតិភោគត្រូវបានចុះបញ្ជីនៅក្នុងអង្គភាពសុរិយោដីដើម្បីធានាការអនុវត្តកាតព្វកិច្ច និងឯកសារច្បាប់ផ្លូវការផ្សេងៗទៀតត្រូវបានបំពេញ នោះធនាគារត្រូវមានកាតព្វកិច្ច ផ្តល់នូវហិរញ្ញប្បទានម្ចាស់គម្រោងនៅក្នុងទំហំទឹកប្រាក់ដែលបានកំណត់នៅក្នុងកិច្ចសន្យា។

### ២.ការបង្វិលទ្រព្យដែលបានដាក់ប្រាតិភោគ

ការបង្កើតនូវប្រាតិភោគវាគ្រាន់តែជាលក្ខខណ្ឌរណបមួយទៅកិច្ចសន្យាចម្បងដែលជាកិច្ចសន្យាផ្តល់នូវហិរញ្ញប្បទាន។ មានន័យថា នៅពេលដែលកាតព្វកិច្ចចម្បងត្រូវបានសងរួចរាល់នោះប្រាតិភោគក៏នឹងត្រូវរលត់ផងដែរ។ ក៏ប៉ុន្តែវាមិនមែនជាការរលត់ដោយស្វ័យប្រវត្តិនោះឡើយ ដោយហេតុថា ប្រាតិភោគត្រូវបានបង្កើតតាមរយៈការចុះបញ្ជីនៅអង្គភាពសុរិយោដី

ហើយ បើចង់រំលត់ការចុះបញ្ជីនោះត្រូវមានការស្នើសុំទៅអង្គភាពសុរិយោដី ដើម្បីលុបការចុះបញ្ជី ស្ដីពីការបង្កើតសិទ្ធិ ប្រាតិភោគនោះ[96]។

## ២. សេចក្ដីសន្និដ្ឋាន

ឆ្លងកាត់តាមការសិក្សាបានឲ្យដឹងថា បរិយាកាសអាជីវកម្មនូវកម្ពុជាពិតជាមានអំណោយផលដល់ការធ្វើអាជីវកម្មលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ។ វាជាការប្រសើរណាស់ក្នុងបរិយាកាសអំណោយផលសេដ្ឋកិច្ចរបស់ទីផ្សារកម្ពុជា ក្នុងការបើកឲ្យមានការប្រកួតប្រជែង សកម្មភាពអាជីវកម្ម លើទីផ្សារសេរីក្នុងទិសដៅឲ្យមានភាពប្រសើរឡើងនូវកំណើនសេដ្ឋកិច្ច លក្ខ-ខណ្ឌរស់នៅល្អប្រសើរ ប្រកបដោយផាសុកភាព ចេរភាព និងស្ថេរភាព។

ដើម្បីសម្រេចនូវទិសដៅនេះ ការប្រើប្រាស់ធនធានហិរញ្ញវត្ថុលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុគឺជាមូលធនដ៏ចាំបាច់បំផុតដើម្បីដាក់ឲ្យមានដំណើរការអាជីវកម្មកម្ពុជា។ ការទទួលបាននូវហិរញ្ញប្បទានពីធនាគារក្នុងការអភិវឌ្ឍន៍គឺជាមធ្យោបាយដ៏ល្អប្រសើរបំផុត។ ក៏ប៉ុន្តែយន្តការនៃការទទួលនូវហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍អចលនវត្ថុ ពុំមែនទទួលបានដោយងាយស្រួលឡើយ គឺតម្រូវឲ្យគ្រឹះស្ថានធនាគារធ្វើការសិក្សាវាយតម្លៃយ៉ាងស៊ីជម្រៅលើលទ្ធភាពសងរបស់កូនបំណុល មុននឹងឈានទៅដល់ការបង្កើតកិច្ចសន្យា ដោយពិនិត្យវាយតម្លៃលើប្រាតិ-ភោគរបស់ម្ចាស់គម្រោង ការសិក្សាអំពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនអភិវឌ្ឍអចលនវត្ថុ ការទស្សន៍ទាយស្ថានភាព អាជីវកម្ម ការតាមដានសកម្មភាពអាជីវកម្មជាដើម។

ចំណែកឯការអនុវត្តសិទ្ធិ និងកាតព្វកិច្ចគឺមានភាពរឹតបន្តឹងយ៉ាងខ្លាំងនៅក្នុងកិច្ចសន្យាដែលគេតែងមើលឃើញថាទំនាក់ទំនងនៃ កិច្ចសន្យារវាងគូភាគីពុំសូវមានសមភាពនោះទេ មានន័យ ថាភាគីធនាគារតែងមានលំដាប់សិទ្ធិខ្ពស់ជាងអ្នកដែលត្រូវបានផ្ដល់ឲ្យនូវកម្ចី។ ក្នុងទិសដៅនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងបង្ការនូវហានិភ័យយ៉ាងខ្ពស់ និងប្រយ័ត្នប្រយែងជាទីបំផុត។

នាពេលបច្ចុប្បន្នគម្រោងអភិវឌ្ឍន៍អចលនវត្ថុគឺ មានដំណើរការទៅមុខយ៉ាងល្អប្រសើរ និងទទួលបាននូវផលចំណេញយ៉ាងច្រើនក្រាស់ក្រែល ហើយការអនុវត្តកាតព្វកិច្ចសងចំពោះ

[96] ប្រកាសអន្តរក្រសួងស្ដីអំពីនីតិវិធីនៃចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

ធនាគារក៏មានភាពរលូនផងដែរ។ ការអភិវឌ្ឍន៍គម្រោងអភិវឌ្ឍន៍អចលនវត្ថុត្រូវបានមើលឃើញថាកំពុងមានសន្ទុះ និងរីកដុះដាលយ៉ាងគំហុក ជាពិសេសជុំវិញរាជធានីភ្នំពេញ។

នាពេលអនាគតដោយអត់យល់អំពីសមារណកម្មលើទីផ្សារអាស៊ាន និងផ្តល់នូវកាលានុវត្តភាពយ៉ាងអំណោយផល ក្នុងការបំពេញនូវសេចក្តីតម្រូវការផ្សេងៗ ក្នុងនោះផងដែរអាផាតមិនសម្រាប់ជួល ខុនដូសម្រាប់លក់ក្នុងគោលបំណងនៃការស្នាក់នៅ ជំនួញអាជីវកម្ម សេវាលំហែកាយក្លឹបសុខភាពដែលនឹងធានាបាននូវសេចក្តីត្រូវការគ្រប់មជ្ឈដ្ឋានរបស់អ្នកវិនិយោគជាតិ អន្តរជាតិ និង ជាពិសេសបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងស្រុក។

# សកម្មភាពរបស់គណៈមេធាវី

# ១. ទំនាក់ទំនងជាតិ និងអន្តរជាតិ

## ១.១ ទំនាក់ទំនងជាតិ

### ប្រធានគណៈមេធាវីជួបពិភាក្សាការងារជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នៅថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវី និងឯកឧត្តម **កើត សេកាណូ** តំណាងក្រសួងយុត្តិធម៌បានជួបប្រជុំពិភាក្សាការងារជាមួយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។





## ការចូលជួបសម្តែងការគួរសម និងពិភាក្សាលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌច្បាប់លើវិស័យយុត្តិធម៌ជាមួយកងរាជអាវុធហត្ថលើផ្ទៃប្រទេស

នាថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៨ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីចូលជួបសម្តែងការគួរសម និងពិភាក្សាលើកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌច្បាប់លើវិស័យយុត្តិធម៌ជាមួយឯកឧត្តម នាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។





## ការចូលជួបសម្ដែងការគួរសម និងពិភាក្សាលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌច្បាប់លើវិស័យយុត្តិធម៌ជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

នាថ្ងៃច័ន្ទ ១២រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រតិភូគណៈមេធាវីរួមមានសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី ចូលជួបសម្ដែងការគួរសម និងពិភាក្សាលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌច្បាប់លើវិស័យយុត្តិធម៌ជាមួយឯកឧត្តម **លឹម ទាន់** រដ្ឋលេខាធិការក្រសួងរៀប ចំដែនដី នគរូបនីយកម្ម និងសំណង់។



## ការចូលជួបសម្ដែងការគួរសម និងពិភាក្សាលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌច្បាប់លើវិស័យយុត្តិធម៌ជាមួយអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ

ការចូលជួបសម្ដែងការគួរសម និងពិភាក្សាលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌច្បាប់លើវិស័យយុត្តិធម៌ជាមួយអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ នាថ្ងៃសុក្រ ១១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ លោកមេធាវី **សួន វិសាល**

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីចូលជួបសម្ដែងការគួរសម និងពិភាក្សាលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌច្បាប់លើវិស័យយុត្តិធម៌ជាមួយឯកឧត្ដមសន្តិបណ្ឌិត **ចាន់ គីមសេង** អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ។





## លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា រួមទាំងក្រុមប្រឹក្សាគណៈមេធាវី បានចុះជួបជាមួយប្រធានពន្ធនាគារខេត្តព្រះសីហនុ

នាថ្ងៃព្រហស្បត្តិ៍ ០៦ កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា រួមទាំងក្រុមប្រឹក្សាគណៈមេធាវីបានជួបប្រជុំពិភាក្សាជាមួយប្រធានពន្ធនាគារខេត្តព្រះសីហនុ ស្តីពី ការផ្តល់បន្ទប់មេធាវី ក្នុងពន្ធនាគារក្នុងការជួបកូនក្តី និងពិគ្រោះយោបល់ដល់កូនក្តីនៅពន្ធនាគារ។ ជាលទ្ធផលពន្ធនាគារខេត្តព្រះសីហនុបានផ្តល់បន្ទប់មួយសម្រាប់មេធាវីជួបកូនក្តី និងពិគ្រោះយោបល់ ។



## លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី ធ្វើដំណើរទៅជួបពិភាក្សាការងារជាមួយប្រធានសាលាដំបូងខេត្តនានាស្តីពី តួនាទីប្រតិភូគណៈមេធាវី

ក្នុងត្រីមាសទី១ឆ្នាំ២០១៨នេះ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី ធ្វើដំណើរទៅកាន់សាលាដំបូងខេត្តស្ទឹងត្រែង ខេត្តរតនគីរី និងខេត្តកណ្តាល ដើម្បីជជែកពិភាក្សាការងារជាមួយប្រធានសាលាដំបូងអំពី តួនាទីរបស់ប្រតិភូគណៈមេធាវីប្រចាំសាលាដំបូងនីមួយៗ។ នៅក្នុងកិច្ចប្រជុំទាំងនោះក៏មានពិភាក្សាអំពី ៖

១) បង្ហាញពីសកម្មភាពការងាររបស់គណៈមេធាវី

២) បង្ហាញសមាសភាពប្រតិភូគណៈមេធាវីតាមខេត្ត និងតួនាទីរបស់ប្រតិភូ

៣) គោលនយោបាយពាក់ព័ន្ធនឹងការទទួលរឿងក្តីការពារជូនជនក្រីក្រ

៤) ការស្នើសុំរៀបចំតុរបស់មេធាវីនៅក្នុងសវនាការ

៥) ការស្នើសុំបន្ទប់នៅក្នុងសាលាដំបូងដើម្បីឲ្យប្រតិភូគណៈមេធាវីតាមខេត្តធ្វើកិច្ចការ។



**នាយកដ្ឋានការពារជនក្រីក្រ នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានចាត់តាំងមេធាវីការពារក្ដីជូនជនក្រីក្រ ដោយឥតគិតកម្រៃ**

ក្នុងត្រីមាសទី១នេះ លោកមេធាវី **លីវ សុវណ្ណា** ប្រធាននាយកដ្ឋានការពារក្ដីជូនជនក្រីក្រ នៃគណៈមេធាវី បានដឹកនាំសមាជិក-សមាជិកា និងក្រុមការងារមេធាវីចុះជួបប្រជាពលរដ្ឋរងគ្រោះ អំពីការឆបោករបស់ក្រុមហ៊ុន Empire Big Capital Limited (EBC) នៅតាមបណ្ដាខេត្តនានា រួមមាន ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង។ នៅក្នុងការជួបជាមួយប្រជាពលរដ្ឋរងគ្រោះទាំងនោះ ក៏មានការជួយសម្របសម្រួលពីស្នងការនគរបាលខេត្តទាំងនោះផងដែរ។



**១.២ ទំនាក់ទំនងអន្តរជាតិ**

**ការពិភាក្សាលើកិច្ចសហប្រតិបត្តិការជាមួយក្រុមអ្នកជំនាញនៃធនាគារពិភពលោក**

នាព្រឹកថ្ងៃអង្គារ ១២រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងលោកមេធាវី **ព្រហ្ម វិចិត្រអភិវឌ្ឍ** អគ្គលេខាធិការនៃគណៈមេធាវីបានទទួលជួបជាមួយ

ក្រុមអ្នកជំនាញនៃធនាគារពិភពលោកដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងវិស័យពាណិជ្ជកម្ម ជាពិសេសបញ្ហាក្ស័យធនដែលក្រុមអ្នកជំនាញនៃធនាគារពិភពលោក មានបំណងជួយគណៈមេធាវីក្នុងការបណ្តុះបណ្តាលមេធាវីពាក់ព័ន្ធនឹងវិស័យនេះ។ ឆ្លើយតបនឹងសំណើនេះ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានស្នើអោយក្រុមអ្នកជំនាញនៃធនាគារពិភពលោក រៀបចំគម្រោង និងពិភាក្សាលំអិតជាមួយនឹងអគ្គលេខាធិការគណៈមេធាវី ដើម្បីអនុវត្តការងារនេះ។





## ២. កិច្ចប្រជុំផ្ទៃក្នុង

### កិច្ចប្រជុំអនុក្រុមការងារ ក្នុងវិស័យរដ្ឋប្បវេណី វិស័យពាណិជ្ជកម្ម និងវិស័យការងារ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

នាថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចប្រជុំអនុក្រុមការងារក្នុងវិស័យការងារអនុក្រុមការងារ ក្នុងវិស័យរដ្ឋប្បវេណី និងអនុក្រុមការងារក្នុងវិស័យពាណិជ្ជកម្ម។ អង្គប្រជុំបានពិភាក្សាពីតួនាទី ភារកិច្ចនៃក្រុមការងារនីមួយៗ និងបានពិភាក្សាកែសម្រួលសមាសភាពនៃអនុក្រុមការងារនីមួយៗ ដើម្បីអោយដំណើរការមានប្រសិទ្ធភាព និងគុណភាព ព្រមទាំងលើកទិសដៅការងារអនុវត្តបន្ត ។






## លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចប្រជុំបុគ្គលិកប្រចាំខែ ដើម្បីបូកសរុបការងារ និងលើកទិសដៅការងារសម្រាប់រៀបចំមហាសន្និបាតប្រចាំឆ្នាំ២០១៨

នាថ្ងៃព្រហស្បត្តិ៍ ១៥កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំកិច្ចប្រជុំបុគ្គលិកប្រចាំខែ ដើម្បីបូកសរុបការងារ និងលើកទិសដៅការងារសម្រាប់ខែបន្ទាប់។ ជាមួយគ្នាផងដែរ នាថ្ងៃសុក្រ ៧កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ និងបានដឹកនាំកិច្ចប្រជុំបុគ្គលិក ដើម្បីត្រួតពិនិត្យការងារប្រចាំខែនិងលើកទិសដៅការងារសម្រាប់រៀបចំមហាសន្និបាតប្រចាំឆ្នាំ២០១៨។ កិច្ចប្រជុំនេះការចូលរួមបុគ្គលិកគ្រប់អង្គភាពទាំងអស់នៃគណៈមេធាវីរួមទាំងលោកអគ្គលេខាធិការ និងអគ្គលេខាធិការរង នៃគណៈមេធាវីផងដែរ។




## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា រៀបចំកិច្ចប្រជុំប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត ក្រោមអធិបតីភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃសុក្រ ១១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា រៀបចំកិច្ចប្រជុំប្រតិភូគណៈមេធាវីប្រចាំរាជ-

ធានី-ខេត្ត ក្រោមអធិបតីភាពលោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សា និងណែនាំពីគោលការណ៍នៃការទទួល បែងចែក និងការចំណាយលើរឿងក្ដីក្រីក្រ ព្រមទាំងបានអនុញ្ញាតឱ្យប្រតិភូគណៈមេធាវីរាយការណ៍ពីលទ្ធផលការងារ និងបញ្ហាប្រឈមនានានៅក្នុងរាជធានី-ខេត្ត ។





## កិច្ចប្រជុំត្រីមាសសម្រាប់ប្រតិភូគណៈមេធាវីប្រចាំខេត្ត

នាថ្ងៃច័ន្ទ ១០កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត ក្រោមអធិបតីភាពលោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារប្រតិភូប្រចាំត្រីមាស ។





# ៣. សិក្ខាសាលា និងការផ្សព្វផ្សាយច្បាប់

## ៣.១ សិក្ខាសាលា

## សិក្ខាសាលាស្តីពី ការបែងចែកមត៌ក

នាថ្ងៃព្រហស្បត្តិ៍ ១៤រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសហការជាមួយសហព័ន្ធគណៈមេធាវីជប៉ុន(JFBA) និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ជប៉ុន (ICD) រៀបចំសិក្ខាសាលា ក្រោមប្រធានបទស្តីពី "ការលែងលះ" ក្រោមអធិបតីភាពលោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ដែលមានការធ្វើបទបង្ហាញដោយមេធាវីរបស់សហព័ន្ធគណៈមេធាវីជប៉ុន និងលោកមេធាវី **នង មាននន្ទ** និងលោកមេធាវី **នាង បញ្ញា**។ ក្នុងកម្មវិធីនេះផងដែរ លោកប្រធានគណៈមេធាវីក៏បានផ្តល់កិត្តិយសចែកជូនដល់វាគ្មិននូវប័ណ្ណថ្លែងអំណរគុណសម្រាប់ការយកចិត្តទុកដាក់ចូលរួមជួយធ្វើឲ្យសិក្ខាសាលានេះអាចដំណើរការទៅបានដោយរលូន និងបានថតរូបជុំគ្នាទុកជាអនុស្សាវរីយ ។



## សិក្ខាសាលាស្ដីពី ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា

នាថ្ងៃច័ន្ទ ៥កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ២០១៨ នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវី នៃ ព្រះរាជាណាចក្រកម្ពុជា និងសមាជិកគណៈមេធាវីចំនួនប្រមាណ៥០រូបបានចូលរួមសិក្ខាសាលា ស្ដីពី ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា រៀបចំដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម សហការ ជាមួយសមាគមកម្មសិទ្ធិបញ្ញាកម្ពុជា គណៈភ្នាក់ងារកម្មសិទ្ធិបញ្ញាជប៉ុន និងគណៈមេធាវី នៃ ព្រះរាជាណាចក្រកម្ពុជា។ ក្នុងឱកាសនេះផងដែរ លោកប្រធានគណៈមេធាវីបានថ្លែងការកត់សំគាល់ក្នុងអង្គសិក្ខាសាលា ដែលមានអត្ថន័យដ៏មានសារៈសំខាន់សម្រាប់សិក្ខាកាមទាំងអស់។




## សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី៦ លើសេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ

នាថ្ងៃសុក្រ ១៥រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ ក្រសួងបរិស្ថានបានប្រារព្ធសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើកទី៦ លើសេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជានៅឯសណ្ឋាគារ

សណ្ឋាគារសូហ្វីតែលក្នុងរាជធានីភ្នំពេញ មុននឹងដាក់ជូនរាជរដ្ឋាភិបាលកម្ពុជាដើម្បីបញ្ជូនទៅកាន់រដ្ឋសភា ក្រោមអធិបតីភាពឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងលោកមេធាវី **សួន វិសាល** ជាប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងអ្នកពាក់ព័ន្ធពីវិស័យច្បាប់ជាច្រើនទៀត ទាំងជាតិ និងអន្តរជាតិ។






## សិក្ខាសាលាស្តីពីច្បាប់និងសេដ្ឋកិច្ច ក្រោមប្រធានបទ "ដើម្បីក្លាយជាមេធាវីល្អសំរាប់កូនក្តី"

នៅថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ ២០១៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសហការជាមួយសាកលវិទ្យាល័យជាតិគ្រប់គ្រង និងសាលាច្បាប់អន្តរជាតិហានដុងបានរៀបចំសិក្ខាសាលាស្តីពីច្បាប់ និងសេដ្ឋកិច្ចក្រោមប្រធានបទ "ដើម្បីក្លាយជាមេធាវីល្អសំរាប់កូនក្តី" ក្រោមអធិបតីភាពលោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានការធ្វើបទបង្ហាញដោយលោក David Prince លោកចៅក្រមកិត្តិយស និងលោកចៅក្រម **ចាយ ច័ន្ទតារាវណ្ណ** ។



## ៣.២ ការផ្សព្វផ្សាយច្បាប់តាមស្ថានីយ៍ទូរស្សន៍បាយ័ន

### កម្មវិធីផ្សព្វផ្សាយច្បាប់ក្រោមកិច្ចសហការរវាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ស្ថានីយទូរទស្សន៍បាយ័ននិងក្រសួងយុត្តិធម៌

នាថ្ងៃសៅរ៍ ១០កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រោមកិច្ចសហការរវាងគណៈមេធាវី និងស្ថានីយ៍ទូរទស្សន៍បាយ័ន ឯកឧត្តម **ខិន ម៉ាលីន**

តំណាងក្រសួងយុត្តិធម៌ ឯកឧត្តម **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **លីវ សុវណ្ណា** ប្រធាននាយកដ្ឋានការពារជនក្រីក្រនៃគណៈមេធាវី បានធ្វើជាវាគ្មិននៅក្នុងកម្មវិធីច្បាប់។ កិច្ចពិភាក្សានេះផ្តោតសំខាន់លើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា សមិទ្ធិផលការងាររបស់គណៈមេធាវី និងការផ្តល់សេវាកម្មមេធាវីដល់ជនក្រីក្រ ក្រោមអាណត្តិនៃការដឹកនាំរបស់ឯកឧត្តម **សួន វិសាល** ប្រធានគណៈមេធាវី។



## គណៈកម្មការព្រឹត្តិបត្រ

| | |
|---|---|
| ១-ឯកឧត្តម សួន វិសាល | ចាងហ្វាងការផ្សាយ |
| ២-លោកមេធាវី កុយ នាម | និពន្ធនាយក |
| ៣-លោកមេធាវី លីវ សុវណ្ណា | លេខាធិការ |

## នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

| | |
|---|---|
| ១-លោកមេធាវី កែ ម៉ុនធឿន | ប្រធាននាយកដ្ឋាន |
| ២-លោកមេធាវី សេង សុខឃីម | អនុប្រធាននាយកដ្ឋាន |
| ៣. លោកស្រីមេធាវី លឹម ច័ន្ទលីដា | អនុប្រធាននាយកដ្ឋាន |
| ៣-លោកមេធាវី ម៉ៃ ច័ន្ទសត្យា | អនុប្រធាននាយកដ្ឋាន |
| ៤-លោកមេធាវី វ៉ា សំរិត | ប្រធានការិ. ព្រឹត្តិបត្រ |
| ៥-លោកមេធាវី ហួត សុវណ្ណា | បុគ្គលិកស្ម័គ្រចិត្ត |
| ៦- លោក ស្រេង សីហាម៉ុននុត | បុគ្គលិកស្ម័គ្រចិត្ត |
| ៧. លោក ជុំ ម៉ុនណារាយ | បុគ្គលិកហាត់ការ |
| ៨. លោក នួន រ៉ា | បុគ្គលិកហាត់ការ |

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

**លោកមេធាវី ឆ បូណាវី**

**លោកមេធាវី សារិន ដេឈ្វ៉ា**

DFDL

**គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា**